ក

មាតិកា

I_ខុទ្ទកាល័យព្រះមហាក្សត្រ

១_ព្រះរាជក្រម

០២-៤-២០០៥ -ព្រះរាជក្រម នស/រកម/០៤០៥/០១០ ច្បាប់ស្តីពីការអនុម័តយល់ព្រម ឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាស្តីពីសារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសសៃប្រសាទ ឆ្នាំ ១៩៧១ ២៥៧៩

២_ព្រះរាជក្រឹត្យ

១២-៤-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៤០៥/១៧២ ស្តីពីការតម្លើងថ្នាក់ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នូវមន្ត្រីរាជការស៊ីវិលរបស់ក្រសួងស្ថាប័ន ២៦៦០

១២-៤-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៤០៥/១៧៣ ស្តីពីការដាក់មន្ត្រីរាជការនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌនិងមុខតំណែងមុខងារសាធារណៈ ដោយនៅបន្តការងារក្នុងមុខតំណែងនយោបាយដដែល ជូនមន្ត្រីរាជការស៊ីវិលរបស់ក្រសួងស្ថាប័ន ២៦៦៧

១២-៤-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៤០៥/១៧៤ ស្តីពីការដាក់មន្ត្រីរាជការនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួង-ស្ថាប័ន ឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ២៦៦៩

១៩-៤-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៤០៥/១៧៩ ស្តីពីការតែងតាំងមន្ត្រីរាជការចំនួន ០៤ រូប ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា ២៦៧១

១៩-៤-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៤០៥/១៨០ ស្តីពី ការប្រោសព្រះរាជទានចំពោះ ឯកឧត្តម **សក់ សេដ្ឋា** នូវគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ២៦៧៣

១៩-៤-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៤០៥/១៨១ ស្តីពីការតែងតាំង ឯកឧត្តម **ស្វាយ សារ៉េត** ជាទីប្រឹក្សាអម ក្រសួងអភិវឌ្ឍន៍ជនបទ បន្ថែមលើមុខងារបច្ចុប្បន្ន មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ២៦៧៤

១៩-៤-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៤០៥/១៨៥ ស្តីពីការតែងតាំងមន្ត្រីរាជការ ២៦៧៥

២១-៤-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៤០៥/១៨៧ ស្តីពីការតែងតាំង ឯកឧត្តម **ចម ប៊ុរិយ** ជាទីប្រឹក្សាសម្តេច ហេង សំរិន អនុប្រធានទី ១ នៃរដ្ឋសភា នីតិកាលទី ៣ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ២៦៧៦

២១-៤-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៤០៥/១៨៨ ស្តីពីការតែងតាំង ឯកឧត្តម **ឈាង ខុន** បច្ចុប្បន្នឯកអគ្គរាជទូតប្រធានបេសកកម្មអចិន្ត្រៃនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការសហប្រជាជាតិ និងអង្គការអន្តជាតិនានា នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស អោយទទួលភារកិច្ចបន្ថែមជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជាប្រចាំ ប្រទេសស្វីស ដោយមាននិវេសនដ្ឋាន នៅទីក្រុងហ្សឺណែវ ២៦៧៧

២១-៤-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៤០៥/១៨៩ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូនវរសេនីយ៍ឯក **អឿង សាមីន** នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ២៦៧៨

២៧-៤-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៤០៥/១៩៣ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន ២៦៧៩√

II~ក្រុមប្រឹក្សាធម្មនុញ្ញ

២៩-៤-២០០៥ -លិខិតលេខ ០៩/២០០៥ កបធ ស្តីពី សេចក្តីថ្លៃយមតិរបស់ក្រុមប្រឹក្សាធម្មនុញ្ញ អំពីសេចក្តីស្នើច្បាប់ធម្មនុញ្ញ សំដៅកែសម្រួលកូរ៉ុមសម្រាប់ប្រជុំរដ្ឋសភា និងព្រឹទ្ធសភា ២៦៨១

III~រាជរដ្ឋាភិបាល

១~អនុក្រឹត្យ

២០-៤-២០០៥ -អនុក្រឹត្យលេខ ៥៦ អនក្រ.បក ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតចំការកៅស៊ូ ស្នួល ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ២៦៨៣

២០-៤-២០០៥ -អនុក្រឹត្យលេខ ៥៧ អនក្រ.បក ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតចំការកៅស៊ូ បឹងកេត ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ២៦៨៥

២០-៤-២០០៥ -អនុក្រឹត្យលេខ ៥៨ អនក្រ.បក ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតចំការកៅស៊ូ ចំការអណ្តូង ជាគ្រឹះស្ថាន សាធារណៈមានលក្ខណៈសេដ្ឋកិច្ច ២៦៨៧

២០-៤-២០០៥ -អនុក្រឹត្យលេខ ៥៩ អនក្រ.បក ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតចំការកៅស៊ូ ពាមជាំង ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ២៦៨៩

២០-៤-២០០៥ -អនុក្រឹត្យលេខ ៦០ អនក្រ.បក ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតចំការកៅស៊ូ ក្រែក ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ២៦៩១

២០-៤-២០០៥ -អនុក្រឹត្យលេខ ៦១ អនក្រ.បក ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតចំការកៅស៊ូ ជុប ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ២៦៨៩

២០-៤-២០០៥ -អនុក្រឹត្យលេខ ៦២ អនក្រ.បក ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតចំការកៅស៊ូ មេមត់ ជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ២៦៩៥

២៨-៤-២០០៥ -អនុក្រឹត្យលេខ ៦៣ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ២៦៩៧

២៩-៤-២០០៥ -អនុក្រឹត្យលេខ ៦៤ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការជាតិ គំរោងផ្លូវដែកសិរីសោភ័ណ-ប៉ោយប៉ែត/បុរី-គុនមីញ ២៦៩៩

២០-៤-២០០៥ -អនុក្រឹត្យលេខ ៣៨២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៧០៣

២០-៤-២០០៥ -អនុក្រឹត្យលេខ ៣៨៣ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២៧០៥

២០-៤-២០០៥ -អនុក្រឹត្យលេខ ៣៨៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២៧១៣

២០-៤-២០០៥ -អនុក្រឹត្យលេខ ៣៨៥ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា ២៧១៦

២៦-៤-២០០៥ -អនុក្រឹត្យលេខ ៣៨៦ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២៧១៨

២៦-៤-២០០៥ -អនុក្រឹត្យលេខ ៣៨៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៧២០

២៦-៤-២០០៥ -អនុក្រឹត្យលេខ ៣៨៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៧២២

២៧-៤-២០០៥ -អនុក្រឹត្យលេខ ៣៨៩ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិ ២៧២៤

២៨-៤-២០០៥ -អនុក្រឹត្យលេខ ៣៩០ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២៧២៦

២៩-៤-២០០៥ -អនុក្រឹត្យលេខ ៣៩១ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ២៧៣៦

២៩-៤-២០០៥ -អនុក្រឹត្យលេខ ៣៩២ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ២៧៣៧

២_សារាចរណែនាំ

២៨-៤-២០០៥ -សារាចរណែនាំលេខ ០១ សរណន ស្តីពីការតែងតាំងមន្ត្រីរាជការ ២៧៣៨ ✓

IV_ការងារបណ្ដាក្រសួង

១_ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១១-៤-២០០៥ -លិខិតលេខ ៨៣៦ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ហ្គ្រីន ហ្វាម** ២៧៣៩

១១-៤-២០០៥ -លិខិតលេខ ៨៣៧ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **សុផារី ពាណិជ្ជ អ៊ីមផត អិចផត** ២៧៤១

១១-៤-២០០៥ -លិខិតលេខ ៨៣៩ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អង្គរ នាគមាស អ៊ីមផត អិចផត** ២៧៤៣

១១-៤-២០០៥ -លិខិតលេខ ៨៤០ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ស៊ីជីន (ខេមបូឌា) អិលធីឌី** ២៧៤៥

១១-៤-២០០៥ -លិខិតលេខ ៨៤២ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **លុណា ជូឌូនណូ** ២៧៤៧

១១-៤-២០០៥ -លិខិតលេខ ៨៤៣ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ស៊ុយ ភាំង អ៊ិនវេសមេន & ឌីវេឡុបមេន** ២៧៤៩

១១-៤-២០០៥ -លិខិតលេខ ៨៤៤ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ខេ.ប៊ី.ភី ត្រេឌីង អ៊ីមផត អិចផត** ២៧៥១

១១-៤-២០០៥ -លិខិតលេខ ៨៤៦ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អេវើ_គ្លូរី (ខេមបូឌា) ហ្គាមេន មេនូហ្វេកឈើរីង** ២៧៥៣

១១-៤-២០០៥ -លិខិតលេខ ៨៤៧ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **រិចឆូត អ៊ីមផត & អិចផត** ២៧៥៤

១១-៤-២០០៥ -លិខិតលេខ ៨៤៩ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អ៊ី អេស ផែរហោវហ្ស៊ីង & លីហ្ស៊ីង** ២៧៥៦

១១-៤-២០០៥ -លិខិតលេខ ៨៥០ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អ៊ី អេស ហ្គាមេន** ២៧៥៨

១១-៤-២០០៥ -លិខិតលេខ ៨៥១ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អ៊ី អេស ឌីវេឡុបមេន & ខនស្ត្រាក់សិន** ២៧៦០

១១-៤-២០០៥ -លិខិតលេខ ៨៥២ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **វីនដាន (ខេមបូឌា)** ២៧៦២

១១-៤-២០០៥	-លិខិតលេខ ៨៥៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **យ៉ាលី ដារ៉ា ត្រេឌីង ម៉ិចកូ**	២៧៦៤
១២-៤-២០០៥	-លិខិតលេខ ៨៥៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អាហ្វេស៊ីប ហ្វ៊ែរ ហ្វេសិន**	២៧៦៦
១២-៤-២០០៥	-លិខិតលេខ ៨៥៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **វើលដ៍ លីង**	២៧៦៧
១២-៤-២០០៥	-លិខិតលេខ ៨៥៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អាអេរូតេម៉ា (ខេមបូឌា) អិលធីឌី**	២៧៦៩
១២-៤-២០០៥	-លិខិតលេខ ៨៥៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អិម អេស អិម គ្លូបល អ៊ិនវេសមេន (ខេមបូឌា)**	២៧៧១
១២-៤-២០០៥	-លិខិតលេខ ៨៥៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ឡាវា អ៊ិនវេសមិន ខូ អិលធីឌី**	២៧៧៣
១២-៤-២០០៥	-លិខិតលេខ ៨៦៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **សុគ័ណ្ឌ ធារី ពាណិជ្ជ**	២៧៧៤
១២-៤-២០០៥	-លិខិតលេខ ៨៦៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **យូរ៉ូប (ខេមបូឌា) អិនវេសមេន**	២៧៧៦
១២-៤-២០០៥	-លិខិតលេខ ៨៦៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ជូ ស៊ីន**	២៧៧៨

២_ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

២២-៤-២០០៥	-ប្រកាសលេខ ៥១៧ អយក.ប្រក ស្តីពី ការបើកអនុវិទ្យាល័យ អូរចំណារ ស្ថិតនៅក្នុង សង្កាត់អូរឧកញ៉ាហេង ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ	២៧៨០
២២-៤-២០០៥	-ប្រកាសលេខ ៥១៨ អយក.ប្រក ស្តីពី ការបើកអនុវិទ្យាល័យ ហ៊ុន សែន ឃ្លាំងលើ ស្ថិតនៅក្នុង សង្កាត់លេខ ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ	២៧៨១
២២-៤-២០០៥	-ប្រកាសលេខ ៥១៩ អយក.ប្រក ស្តីពី ការបើកអនុវិទ្យាល័យ ហ៊ុន សែន អណ្តូងថ្ម ស្ថិតនៅក្នុង សង្កាត់អណ្តូងថ្ម ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ	២៧៨២
២២-៤-២០០៥	-ប្រកាសលេខ ៥២០ អយក.ប្រក ស្តីពី ការប្តូរឈ្មោះអនុវិទ្យាល័យ " សំរោងធំ " ទៅជា អនុវិទ្យាល័យ " សាន់នី វូ សំរោងធំ " ស្ថិតនៅក្នុង ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល	២៧៨៣

ព្រះរាជក្រម

នស/រកម/០៤០៥/០១០

យើង

ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់ យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាស្តីពីសារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទឆ្នាំ ១៩៧១ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ២ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ច្បាប់

ស្តីពី

ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុង អនុសញ្ញាស្តីពីសារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទឆ្នាំ ១៩៧១

មាត្រា ១.-

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាស្តីពីសារធាតុដែល ធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទឆ្នាំ ១៩៧១ ដែលធ្វើនៅទីក្រុងវីយែន នាថ្ងៃទី ២១ ខែ កុម្ភ ឆ្នាំ ១៩៧១ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញា នេះ ។

ធ្វើនៅព្រះបរមរាជវាំង. រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរ/ល.០៥០៤.០៨១

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ហត្ថលេខា និងព្រះហស្តលេខា
ស ខេង នរោត្តម សិរីវុឌ្ឍ

លេខ ...៥៥ . ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ ...០៧ ឆ្នាំ២០...
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឈាង តាន់

អនុសញ្ញា

ស្តីពី

សារធាតុដែលធ្វើអោយប៉ះពាល់ប្រព័ន្ធ សរសៃប្រសាទ

ឆ្នាំ ១៩៧១

អង្គការសហប្រជាជាតិ

អនុសញ្ញាឆ្នាំ ១៩៧១

ស្តីពី

សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ

បុព្វកថា

ភាគីទាំងឡាយ

ដោយមានការបារម្ភដល់ សុខភាពខាងរាងកាយ និង សុខភាពខាងសីលធម៌របស់មនុស្សជាតិ

ដោយមានកង្វល់ចំពោះបញ្ហាសុខភាពជាសាធារណៈ និង បញ្ហាសង្គមដែលបណ្តាលមកពីការប្រើបំពានសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទមួយចំនួន

ដោយបានកំណត់ច្បាស់ថាត្រូវតែការពារនិងត្រូវតែប្រយុទ្ធប្រឆាំងនឹងការប្រើបំពាននៃសារធាតុទាំងនោះ និង ការចរាចរខុសច្បាប់នៃសារធាតុទាំងនោះ

ដោយពិនិត្យឃើញថា ចាំបាច់ត្រូវតែមានវិធានការដ៏ជាក់លាក់ដើម្បីកំណត់ព្រំដែនក្នុងការប្រើប្រាស់សារធាតុទាំងនោះក្នុងគោលដៅត្រឹមត្រូវច្បាប់

ដោយទទួលស្គាល់ថា ការប្រើប្រាស់សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទក្នុងគោលដៅផ្នែកវេជ្ជសាស្ត្រ និង ផ្នែកវិទ្យាសាស្ត្រគឺជាការខានមិនបាន ហើយលទ្ធភាពផ្តល់អោយសារធាតុក្នុងគោលដៅទាំងនេះមិនត្រូវកាត់បន្ថយដោយមិនសមហេតុសមផលនោះទេ

ដោយជឿជាក់ថា ដើម្បីមានប្រសិទ្ធភាព វិធានការទាំងឡាយដែលប្រើប្រាស់ប្រឆាំងទប់ទល់នឹងការប្រើបំពានសារធាតុអស់ទាំងនេះ ត្រូវតែមានលក្ខណៈសហការ និងសកល

ដោយទទួលស្គាល់សមត្ថកិច្ចរបស់អង្គការសហប្រជាជាតិក្នុងការត្រួតពិនិត្យសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និង ចង់អោយអង្គការអន្តរជាតិដែលពាក់ព័ន្ធទាំងអស់ធ្វើសកម្មភាពក្នុងក្របខ័ណ្ឌអង្គការសហប្រជាជាតិ នោះ

ដោយជឿជាក់ថា ចាំបាច់ត្រូវតែមានអនុសញ្ញាអន្តរជាតិមួយសំរាប់ធ្វើអោយសំរេចគោលដៅទាំងអស់នេះ

បានព្រមព្រៀងគ្នាដូចតទៅនេះ:

មាត្រា១ : អត្ថន័យក្រមនៃពាក្យ

លើកលែងតែមានការបញ្ជាក់ប្រាកដប្រជាថាមានន័យផ្ទុយឬលើកលែងតែបរិបទតំរូវអោយមានន័យផ្សេង ពាក្យនានាដូចតទៅក្នុងអនុសញ្ញានេះមានន័យបញ្ជាក់ដូចខាងក្រោម :

ក./ ពាក្យ " ក្រុមប្រឹក្សា " មានន័យថា ក្រុមប្រឹក្សាសេដ្ឋកិច្ច និង សង្គមកិច្ចរបស់អង្គការសហប្រជាជាតិ ។

ខ./ ពាក្យ " គណៈកម្មការ " មានន័យថា គណកម្មការគ្រឿងញៀនរបស់ក្រុមប្រឹក្សា ។

គ./ ពាក្យ " ក្រុមប្រឹក្សា " មានន័យថា ក្រុមប្រឹក្សារបស់អន្តរជាតិត្រួតពិនិត្យគ្រឿងញៀន ដែលបានបង្កើតឡើង ដោយអនុសញ្ញាទោលស្តីពីគ្រឿងញៀនឆ្នាំ១៩៦១ ។

ឃ./ ពាក្យ "អគ្គលេខាធិការ " មានន័យថា អគ្គលេខាធិការអង្គការសហប្រជាជាតិ ។

ង./ពាក្យ "សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ"មានន័យថារាល់សារធាតុទាំងអស់នោះទោះជាមានប្រភពពីធម្មជាតិ រឺពីសំយោគក្តី រឺ ក៏រាល់ផលិតផលធម្មជាតិនៃតារាងទី ១ ទី២ ទី៣ រឺ ទី៤ ។

ច./ ពាក្យ "ការផ្សំ "មានន័យថា:

1./ រាល់សូលុយស្យុងរឺល្បាយទោះជារូបភាពរបស់វាបែបណាក៏ដោយវាមានសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទមួយ រឺច្រើន រឺ

2./ សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទមួយ រឺ ច្រើន ដែលបំបែកតាមរូបមន្តប្រើប្រាស់ ។

ឆ./ ពាក្យ "តារាងទី១" "តារាងទី២" "តារាងទី៣" និង "តារាងទី៤" មានន័យថា បញ្ជីសារធាតុប៉ះពាល់ប្រពន្ធ័សរសៃប្រសាទដែលមានលេខរៀងជាហូរហែរ ជាឧបសម័ន្ធនៃអនុសញ្ញានេះ បញ្ជីអាចនឹងកែប្រែ បានស្រប តាមមាត្រាទី២

ជ./ ពាក្យ "នាំចេញ" និង "នាំចូល"មានន័យនីមួយៗទៅតាមការសន្មតយកដោយឡែករបស់វាគឺជាការផ្ទេរសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទពីរដ្ឋមួយទៅរដ្ឋមួយទៀត ។

ឈ./ ពាក្យ "ការធ្វើ" មានន័យថា រាល់ប្រតិបត្តិការទាំងអស់ដែលនាំអោយបានសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និង រួមមានទាំងការបន្សុទ្ធ និង ការបំលែងសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទអោយទៅជាសារធាតុប៉ះពាល់ប្រពព័ន្ធសរសៃផ្សេងទៀត ។ ពាក្យនេះមានរួមទំាងការធ្វើនៃការផ្សំដែរក្រៅពីការផ្សំទាំងឡាយ ដែលបាន ធ្វើនៅក្នុងឱសថស្ថាន តាមរយៈវេជ្ជបញ្ជា ។

ញ./ ពាក្យ " ចរាចរខុសច្បាប់ " មានន័យថាការធ្វើការចរាចរសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទដែលបានធ្វើផ្ទុយពីបទបញ្ញត្តិនៃអនុសញ្ញានេះ ។

ង./ ពាក្យ " តំបន់ " មានន័យថារាល់ផ្នែករបស់រដ្ឋដែលតាមន័យនៃមាត្រា២៨ ត្រូវបានចាត់ទុកដូចជាអង្គភាពដោយឡែកក្នុងគោលដៅនៃអនុសញ្ញានេះ ។

ច./ ពាក្យ "ទីកន្លែង" មានន័យថា អាគារ ឬ ផ្នែកនៃអាគារព្រមទាំងទីធ្លាដែលភ្ជាប់ទៅនឹងអាគារនោះរឺទៅនឹងផ្នែកនៃអាគារនោះ ។

មាត្រា២ : វិសាលភាពនៃការត្រួតពិនិត្យសារធាតុ

១. បើប្រសិនជាភាគីណាមួយ រឺ អង្គការសុខភាពពិភពលោកមានពត៌មានទាក់ទងនឹងសារធាតុមួយដែលមិនទាន់បានដាក់នៅក្រោមការត្រួតពិនិត្យជាអន្តរជាតិដែលតាមមតិរបស់ភាគីនោះ រឺ អង្គការនោះចាំបាច់ត្រូវបញ្ចូលវាទៅក្នុងតារាងណាមួយនៃអនុសញ្ញានេះភាគីនោះ រឺអង្គការសុខភាពពិភពលោកនោះ ត្រូវធ្វើជាលិខិតជូនដំណឹងជំរាបទៅអគ្គលេខាធិការ ដោយបានភ្ជាប់មកជាមួយគ្រប់ពត៌មាន សមហេតុផលទាំងអស់។ នីតិវិធីនេះត្រូវអនុវត្តដូចគ្នាដែរ ចំពោះភាគី រឺ អង្គការសុខភាពពិភពលោកដែលមានពត៌មានបញ្ជាក់ពីការត្រូវផ្ទេរសារធាតុមួយពីតារាងមួយទៅតារាងមួយទៀត រឺ ក៏លុបឈ្មោះសារធាតុនោះ ចេញពីតារាងណាមួយ ។

២. អគ្គលេខាធិការត្រូវបញ្ជូនលិខិតជូនដំណឹងនេះ និងពត៌មាន ដែលលោកយល់ឃើញថា សមហេតុសមផល ជូនទៅភាគី ទៅគណៈកម្មការ ហើយបើប្រសិនជាលិខិតជូនដំណឹងត្រូវបានធ្វើឡើងដោយ ភាគីណាមួយវិញនោះ គេត្រូវបញ្ជូនលិខិតទៅអង្គការសុខភាពពិភពលោក ។

៣. បើប្រសិនជាពត៌មានដែលភ្ជាប់មកជាមួយនឹងលិខិតជូនដំណឹងនេះបង្ហាញថា សារធាតុដូចបានពោលមកនោះ អាចបញ្ចូលទៅក្នុងតារាងទី១ រឺ តារាងទី២បានតាមន័យនៃកថាខ័ណ្ឌទី ៤ សំរាប់ជាពន្លឺដល់ពត៌មានដែលភាគីខ្លួនទីងមានពីភាគីនឹងត្រូវពិនិត្យលទ្ធភាពអនុវត្តជាបណ្តោះអាសន្នលើសារធាតុមួយនោះ នូវវិធានការត្រួតពិនិត្យទាំងអស់ដែលអាចអនុវត្តបានចំពោះសារធាតុក្នុងតារាងទី១ រឺ តារាងទី២ អោយទៅតាមករណី ។

៣. បើប្រសិនជា អង្គការសុខភាពពិភពលោកបានសំគាល់ឃើញ :

ក./ ថាសារធាតុដូចបានពោលនោះអាចបង្កអោយមាន

i / 1. សភាពនៃអនិស្សរភាព និង

2. ការលើកកំលាំង រឺការបន្ថយកំលាំងប្រព័ន្ធសរសៃប្រសាទកណ្តាល ដែលបណ្តាលអោយមានការមមាល រឺ សៅហ្មងដល់មុខងារចលករ រឺដល់ការយល់ឃើញ រឺដល់ការប្រព្រឹត្ត រឺដល់ការដឹងដោយវិញ្ញាណ

រឺដល់អារម្មណ៍រឺ

ii/ ការប្រើបំពាន និងផលអាក្រក់អាចប្រៀបធៀបទៅនឹងការប្រើបំពាន និង ផលអាក្រក់នៃសារធាតុ ក្នុងតារាងទី១ ទី២ ទី៣រឺទី៤បាន និង

ខ./ ថាមានហេតុផលគ្រប់គ្រាន់អាចឱ្យជឿបានថា សារធាតុនោះបណ្តាលអោយ រឺ មុខជានឹងបណ្តាលអោយមានការប្រើបំពានដូចដែលសារធាតុនោះបង្ករជាបញ្ហាសុខភាពសាធារណៈ និង ជាបញ្ហាសង្គមដែលតំរូវអោយសារធាតុនោះត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យមានលក្ខណៈអន្តរជាតិ អង្គការសុខភាពពិភពលោកនឹងជូនដំណឹងពីការវាយតំលៃសារធាតុមួយនោះទៅគណកម្មការក្នុងនោះអង្គការសុខ ភាពពិភព លោកត្រូវបញ្ជាក់ជាអាទិ៍ ពីរង្វាស់រង្វាល់ ដែលសារធាតុអាចបណ្តាលអោយមាន រឺមុខជានឹងបណ្តាលអោយមានការប្រើបំពាន ពីកំរិតធ្ងន់ធ្ងរនៃបញ្ហាសុខភាពសារធារណៈនិងសង្គមនិងពីកំរិតប្រើបាស់សារធាតុ ក្នុងការព្យាបាលព្រមទាំងធ្វើអនុសាសន៍ពីវិធានការផ្សេង១ ជាយថាហេតុសំរាប់ត្រួតពិនិត្យកាលបើការបញ្ជាក់ទាំងនោះវាសមហេតុផលសំរាប់ជាបំភ្លឺដល់ការវាយតំលៃនេះ ។

៥. ដោយគិតដល់ការជូនដំណឹងរបស់អង្គការសុខភាពពិភពលោក ដែលវាយតំលៃបានច្បាស់លាស់ខាងផ្នែកវេជ្ជសាស្ត្រ និង វិទ្យាសាស្ត្រ និង ដោយយកចិត្តទុកដាក់ពីកត្តាសេដ្ឋកិច្ច សង្គមកិច្ច គតិយុត្ត រដ្ឋបាល និងកត្តាផ្សេងទៀតដែលគណៈកម្មការយល់ឃើញថាសមហេតុសមផលនោះ គណៈកម្មការអាចនឹងបញ្ចូលសារធាតុដូចបានពោលមកនោះបន្ថែមទៅក្នុងតារាងទី១ទី២ ទី៣ រឺ ទី៤ ។ គណៈកម្មការ នេះអាចទាមទារសុំពត៌មានបន្ថែម ពីអង្គការសុខភាពពិភពលោក រឺ ពីប្រភពដទៃទៀតដែលសមស្រប ។

៦. បើប្រសិនជា លិខិតជូនដំណឹងដែលធ្វើតាមន័យនៃកថាខ័ណ្ឌទី១ ទាក់ទងទៅនឹងលក្ខណៈនៃសារធាតុមួយ ចុះបញ្ជីក្នុងតារាងណាមួយរួចហើយនោះ អង្គការសុខភាពពិភពលោកត្រូវបញ្ជូនទៅគណៈកម្មការ ពីការកត់សំគាល់ឃើញថ្មី១របស់ខ្លួនក៏ដូចជារាល់ការវាយតំលៃថ្មី១នៃសារធាតុមួយនោះ ដែលអង្គការសុខភាពពិភពលោក អាចធ្វើដោយអនុលោមតាមបទបញ្ញត្តិនៃកថាខ័ណ្ឌទី ៤ ព្រមទាំងរាល់អនុសាសន៍ថ្មី១ ទាំងអស់ដែលនិយាយពីវិធានការត្រួតពិនិត្យដែលទំនងសមស្របចំពោះអង្គការសុខភាពពិភពលោក សំរាប់យកមកបំភ្លឺដល់ការវាយតំលៃដូចបានពោលមកហើយនោះ ។ ដោយគិតដល់ការជូនដំណឹងដែលបានទទួលពីអង្គការសុខភាពពិភពលោកស្របតាមកថាខ័ណ្ឌ ៥ ក៏ដូចជាកត្តាផ្សេង១ ដែលរៀបរាប់ក្នុងកថាខ័ណ្ឌដូចបានពោលមក ហើយនោះគណៈកម្មការអាចសំរេចផ្ទេរសារធាតុពីតារាងមួយទៅតារាងមួយទៀត រឺ លុបឈ្មោះចោលចេញពីតារាងទាំងនោះ ។

...

៧. រាល់សេចក្តីសំរេចរបស់គណៈកម្មការដែលបានធ្វើតាមន័យនៃមាត្រានេះ អគ្គលេខាធិការនឹងជូនដំណឹងទៅគ្រប់រដ្ឋទាំងអស់ដែលជាសមាជិកនៃអង្គការសហប្រជាជាតិ ទៅរដ្ឋទាំងឡាយដែលមិនមែនជាសមាជិកភាគីនៃអនុសញ្ញានេះ ទៅអង្គការសុខភាពពិភពលោក និងទៅក្រុមប្រឹក្សា ។ សេចក្តីសំរេចនេះចាប់អនុវត្តយ៉ាងពេញលេញចំពោះភាគីនីមួយៗ ក្រោយពីកាលបរិច្ឆេទជូនដំណឹងទៅភាគីនីមួយៗនោះ អស់រយៈពេល ១៨០ ថ្ងៃលើកលែងតែចំពោះភាគីមួយដែលទៅក្នុងរយៈពេលនោះ និង ចំពោះប្រធានបទនៃសេចក្តីសំរេច មានសាច់រឿងត្រូវបញ្ចូលសារធាតុទៅក្នុងតារាង ត្រូវបានផ្តល់ពិមានជាលាយល័ក្ខអក្សរទៅអគ្គលេខាធិការ ថាដោយសារហេតុផលស្ថានការណ៍ដោយឡែកផ្សេងៗ ភាគីនោះពុំអាចមានវិធានការអោយសារធាតុមួយនោះ គោរពតាមបទបញ្ញត្តិទាំងអស់ដែលអនុវត្តន៍ បានចំពោះសារធាតុក្នុងតារាងមួយនៃអនុសញ្ញាបានទេ ។ លិខិតជូនដំណើងប្រភេទបែបនេះត្រូវបញ្ជាក់ពីមូលហេតុនៃសេចក្តីសំរេចដោយឡែកនោះ ។ ទោះជាមានលិខិតជូនដំណើងនេះក៏ដោយ ភាគីនីមួយៗ ត្រូវតែអនុវត្តយ៉ាងតិចបំផុតវិធានការត្រួតពិនិត្យដូចមានរៀបរាប់តទៅ នេះ ។

ក./ភាគីដែលបានធ្វើលិខិតជូនដំណឹងពីសេចក្តីសំរេចបែបនេះទៅអគ្គលេខាធិការ ដែលមានប្រធានបទនិយាយពីសារធាតុមួយដែលរហូតមកទល់នឹងពេលនេះ មិនទាន់បានដាក់អោយឋិតនៅក្រោមការត្រួតពិនិត្យ និង មិនទាន់បានបញ្ចូលបន្ថែមទៅក្នុងតារាងទី ១ ត្រូវតែគិតពីវិធានការត្រួតពិនិត្យពិសេសៗដូចបានរៀបរាប់ក្នុងមាត្រា ៧ តាមលទ្ធភាពដែលមាន ហើយចំពោះសារធាតុនោះត្រូវតែ :

i/ តំរូវអោយមានអាជ្ញាប័ណ្ណចំពោះរការធ្វើ ចំពោះពាណិជ្ជកម្ម និង ចំពោះការចែកចាយសារធាតុនោះ ដោយអនុលោមតាមបទបញ្ញត្តដូចបានគ្រោងទុកក្នុងមាត្រា ៨ ចំពោះសារធាតុក្នុងតារាងទី ២

ii/ តំរូវអោយសារធាតុនោះផ្តល់អោយ ឬ ចែកអោយប្រើបានតាមវេជ្ជបញ្ជា ពេទ្យដោយអនុលោមតាមបទបញ្ញត្តិដូចបានគ្រោងទុកក្នុងមាត្រា ៩ ចំពោះសារធាតុក្នុងតារាងទី ២

iii/ គោរព តាមកាតព្វកិច្ចផ្សេងៗដែលទាក់ទងនឹងការនាំចេញ និង ការនាំចូលដូចមានចែងក្នុងមាត្រា ១២ លើកលែងតែទាក់ទងនឹងភាគីមួយទៀតដែលភាគីនោះ បានជំរាបជូនទៅអគ្គលេខាធិការតាមរយៈលិខិតជូនដំណឹងពីប្រធានបទនិយាយពីសារធាតុ ដូមមាននិយាយនោះ

iv/ គោរពតាមកាតព្វកិច្ចផ្សេងៗដូចមានចែងក្នុងមាត្រា ១៣ ស្តីពីការហាមឃាត់ ឬ ការកាត់បន្ថយការនាំចេញ និង ការនាំចូល ចំពោះសារធាតុនៃតារាងទី ២

v/ ផ្តល់ជូនដល់អង្គការនូវរបាយការណ៍ស្ថិតិ ស្របតាមបទបញ្ញត្តនានានៃវគ្គ ក កថាខ័ណ្ឌទី ៤ នៃមាត្រា ១៦ និង

vi/ ចាត់វិធានការ ស្របតាមបទបញ្ញត្តិនៃមាត្រា២២ ក្នុងចេតនាបង្ក្រាបរាល់អំពើដែលផ្ទុយនឹងច្បាប់ រឺបទបញ្ជាដែលបានអនុម័តពេលអនុវត្តកាតព្វកិច្ចខាងលើនេះ ។

ខ./ភាគីដែលបានធ្វើលិខិតជូនដំណឹងពីសេចក្តីសំរេចបែបនេះទៅអគ្គលេខាធិការ ដែលមានប្រធានបទនិយាយពីសារធាតុមួយដែលរហូតមកទល់ពេលនេះមិនទាន់បានដាក់អោយស្ថិតនៅក្រោមការត្រួតពិនិត្យ និង មិនទាន់បានបញ្ចូលបន្ថែមក្នុងតារាងទី២ សំរាប់សារធាតុនោះ ភាគីត្រូវតែ :

i/ ត្រូវអោយមានអាជ្ញាប័ណ្ណចំពោះការធ្វើចំពោះពាណិជ្ជកម្ម និង ចំពោះការចែកចាយសារធាតុមួយនោះ ដោយអនុលោមតាមបញ្ញត្តិនៃមាត្រា ៨

ii/ ត្រូវអោយសារធាតុមួយនោះផ្តល់ឱ្យ រឺ ចែកអោយប្រើ បានតែតាមវេជ្ជបញ្ជា ដោយអនុលោមតាមបទបញ្ញត្តិនៃមាត្រា៩

iii/ គោរពតាមកាតព្វកិច្ចដែលទាក់ទងទៅនឹងការនាំចេញ និងនាំចូលដូចមានចែងក្នុងមាត្រា ១២ លើកលែងតែទាក់ទងទៅនឹងភាគីមួយទៀត ដែលភាគីនោះបានជំរាបទៅអគ្គលេខាធិការតាមរយៈលិខិតជូនដំណឹងមួយនិយាយពីប្រធានបទសារធាតុដូចមាននិយាយនោះ

iv/គោរពតាមកាតព្វកិច្ចដូចមានចែងក្នុងមាត្រា ១៣ ស្តីពីការហាមឃាត់ រឺបន្ថយការនាំចេញ និងនាំចូល

v/ ផ្តល់ជូនទៅអង្គការនូវរបាយការណ៍ស្ថិតិដោយអនុលោមតាមបទបញ្ញត្តិនៃវគ្គ ក គ និង ឃ នៃកថាខ័ណ្ឌ ៤ របស់មាត្រា១៦ និង

vi/ ចាត់វិធានការសមស្របនឹងបទបញ្ញត្តិនៃមាត្រា ២២ ក្នុងគោលដៅបង្ក្រាបរាល់អំពើដែលផ្ទុយនឹងច្បាប់ រឺ បទបញ្ជាដែលបានអនុម័តនៅពេលអនុវត្តកាតព្វកិច្ចខាងលើនេះ ។

គ./ភាគីដែលបានធ្វើលិខិតជូនដំណឹងពីសេចក្តីសំរេចបែបនេះ ដែលមានប្រធានបទនិយាយពីសារធាតុមួយ ដែលរហូតមកទល់ពេលនេះនៅមិនទាន់បានដាក់អោយស្ថិតនៅក្រោមការត្រួតពិនិត្យ និងមិនទាន់បានបញ្ចូលបន្ថែមទៅក្នុងតារាងទី ៣ សំរាប់សារធាតុនោះភាគីត្រូវតែ :

i/ តំរូវអោយមានអាជ្ញាប័ណ្ណ ចំពោះការធ្វើ ចំពោះពាណិជ្ជកម្ម និងចំពោះការចែកចាយ នៃសារធាតុនោះដោយអនុលោមតាមបទបញ្ញត្តិនៃមាត្រា ៨

ii/ តំរូវអោយសារធាតុនោះផ្តល់អោយ រឺ ចែកអោយប្រើបានតែតាមវេជ្ជបញ្ជាស្របតាមបទបញ្ញាត្តិនៃមាត្រា ៩

iii/ គោរពតាមកាតព្វកិច្ចដែលទាក់ទងនឹងការនាំចេញ ដូចមានចែងក្នុងមាត្រា ១២ លើកលែងតែទាក់ទងទៅនឹងភាគីមួយទៀត ដែលភាគីនោះបានជំរាបជូនអគ្គលេខាធិការតាមរយៈ លិខិតជូនដំណឹងមួយពីប្រធានបទ និយាយពីសារធាតុដូចនិយាយនោះ

iv/ គោរពតាមកាតព្វកិច្ចដូចមានចែងក្នុងមាត្រា ១៣ រឺការបន្ថយការនាំចេញ និងការនាំចូល និង

v/មានវិធានការស្របនឹងបទបញ្ញត្តិនៃមាត្រា ២២ក្នុងគោលដៅបង្ក្រាបរាល់អំពើដែលផ្ទុយនឹងច្បាប់ រឺបទបញ្ជាដែលបានអនុម័តពេលអនុវត្តកាតព្វកិច្ចខាងលើនេះ ។

ឃ./ភាគីដែលបានធ្វើលិខិតជូនដំណឹងពីសេចក្តីសំរេចបែបនេះទៅ អគ្គលេខាធិការដែលមានប្រធានបទនិយាយពីសារធាតុមួយដែលរហូតមកទល់នឹងពេលនេះ នៅមិនទាន់ដាក់ក្រោមការត្រួតពិនិត្យហើយមិនទាន់បានបញ្ចូលបន្ថែមក្នុងតារាងទី ៤ សំរាប់សារធាតុនោះភាគីត្រូវតែ :

i/ តំរូវអោយមានអាជ្ញាប័ណ្ណចំពោះការធ្វើ ចំពោះពាណិជ្ជកម្ម និងចំពោះការចែកចាយនៃសារធាតុមួយនោះដោយអនុលោមតាមបទបញ្ញត្តិនៃមាត្រា ៨

ii/ គោរព តាមកាតព្វកិច្ចដូចមានចែងក្នុងមាត្រា ១៣ ស្តីពីការហាមឃាត់ រឺបន្ថយការនាំចេញ និងនាំចូល និង

iii/ មានវិធានការសមស្របនឹងបទបញ្ញត្តិនៃមាត្រា ២២ ក្នុងគោលដៅបង្ក្រាបរាល់អំពើដែលផ្ទុយនឹងច្បាប់ រឺបទបញ្ជាដែលបានអនុម័តពេលអនុវត្តកាតព្វកិច្ចខាងលើនេះ ។

ង./ ភាគីដែលបានធ្វើលិខិតជូនដំណឹងពីសេចក្តីសំរេចបែបនេះ ទៅអគ្គលេខាធិការដែលមានប្រធានបទនិយាយពីសារធាតុមួយផ្ទេរចូលទៅក្នុងតារាងមួយដែលនៅក្នុងតារាងនោះ វិធានការត្រួតពិនិត្យ និងកាតព្វកិច្ចដែលតឹងរឹងជាងមុន អាចអនុវត្តបាន និង អនុវត្តយ៉ាងតិចបំផុតនូវបទបញ្ញត្តទាំងឡាយនៃអនុសញ្ញានេះ ដែលអាចអនុវត្តបានចំពោះតារាងដែលសារធាតុមួយនោះបានផ្ទេរចេញមកពីនោះ ។

៨. ក./ សេចក្តីសំរេចរបស់គណៈកម្មការ ដែលមានតាមន័យនៃមាត្រានេះ នឹងត្រូវក្រុមប្រឹក្សាធ្វើការសើរើ បើប្រសិនជាមានភាគីមួយស្នើសុំអោយសើរើនៅក្នុងកំឡុងនៃរយៈពេល ១៨០ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងនៃសេចក្តីសំរេច ។ សំណើសុំសើរើត្រូវតែដាក់ជូនទៅអគ្គលេខាធិការជាមួយគ្នានឹងពត៌មានដែលពាក់ព័ន្ធទាំងអស់ដែលជាមូលហេតុនៃសំណើនោះ ។

ខ./ អគ្គលេខាធិការនឹងផ្តល់ជូនច្បាប់ចំលងពីសំណើសើរើ និង ពត៌មានដែលពាក់ព័ន្ធទៅគណៈកម្មការ ទៅអង្គការសុខភាពពិភពលោក និង ទៅគ្រប់ភាគីទាំងអស់ដោយស្នើសុំអោយភាគីទាំងនោះផ្តល់ដំណឹងពីការសង្កេតរបស់ខ្លួនក្នុងរយៈពេលកៅសិបថ្ងៃមកអគ្គលេខាធិការវិញ។ រាល់ការសង្កេតដែលបាន ទទួលទាំងអស់ត្រូវដាក់ជូនក្រុមប្រឹក្សាដើម្បីពិនិត្យពិចារណា ។

គ./ ក្រុមប្រឹក្សាអាចយល់ព្រមកែសំរួលរឺលុបចោលនូវសេចក្តីសំរេចរបស់គណៈកម្មការ។ ការសំរេចរបស់ក្រុមប្រឹក្សាត្រូវជូនដំណឹងទៅគ្រប់រដ្ឋសមាជិកទាំងអស់របស់អង្គការសហប្រជាជាតិ ទៅរដ្ឋដែលមិនមែនជាភាគីសមាជិកនៃអនុសញ្ញា ទៅគណៈកម្មការ ទៅអង្គការសុខភាពពិភពលោកនិង ទៅក្រុមប្រឹក្សា ។

ឃ./នៅពេលកំពុងដំណើរការនីតិវិធីនៃការសើរើ សេចក្តីសំរេចរបស់គណៈកម្មការនៅតែស្ថិតនៅជាធរមានដដែលលើកលែងតែបទបញ្ញត្តិកថាខ័ណ្ឌ ៧ ។

៩. ភាគីនឹងធ្វើអ្វីៗទាំងអស់ដែលស្ថិតនៅក្នុងអំណាចរបស់ខ្លួន ដើម្បីដាក់ឱ្យស្ថិតនៅក្រោមវិធានការឃ្លាំមើល ក៏ដូចជាវិធានការអនុវត្តនូវសារធាតុដែលអនុសញ្ញានេះមិនបានចែងបញ្ជាក់ ប៉ុន្តែសារធាតុទាំងនោះអាចយកទៅប្រើសំរាប់ការធ្វើសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទដោយខុសច្បាប់បាន។

មាត្រា៣ : បទបញ្ញត្តិពិសេសទាក់ទងនឹងការត្រួតពិនិត្យ ការផ្សំ

១. លើកលែងតែមានអ្វីដែលចែងនៅក្នុងកថាខ័ណ្ឌបន្ទាប់នៃមាត្រានេះ ការផ្សំត្រូវស្ថិតនៅក្រោមវិធានការត្រួតពិនិត្យដូចសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទនោះដែរ បើការផ្សំប្រើសារធាតុមួយនោះ ហើយប្រសិនបើជាការផ្សំមានសារធាតុបែបនេះច្រើនលើសពីមួយនោះ វិធានការត្រួតពិនិត្យលើការផ្សំ ដែលមានសារធាតុទាំងនោះត្រូវកាន់តែតឹងរឹងខ្លាំងថែមទៀតដែរ ។

២. បើប្រសិនជា ការផ្សំប្រើសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទក្រៅពីសារធាតុនៃតារាងទី១ ដែលការផ្សំនោះ ត្រូវបានផ្សំតាមរបៀបដែលបង្ហាញឱ្យឃើញថា មានតែគ្រោះថ្នាក់ប្រើបំពានដ៏តិចតួច រឺ គ្មានសោះ និងថាសារធាតុមួយនោះ មិនអាចនឹងប្រមូលយកមកវិញបានជាចំនួនច្រើន ដែលអាចបណ្តាលអោយ

មានការប្រើបំពានតាមរយៈមធ្យោបាយដំរាយអនុវត្តផ្សេងៗ ហើយនិងថាតាមលក្ខណៈសមស្រប ការផ្សំនេះមិនបង្កអោយមានបញ្ហាទាំងខាងសុខភាពសាធារណៈ ទាំងខាងសង្គម នោះការផ្សំដូចបានជំរាបមកនេះអាចរួចផុតពីវិធានការត្រួតពិនិត្យមួយចំនួនដូចមានចែងក្នុងអនុសញ្ញានេះស្របតាមកថាខ័ណ្ឌទី ៣ ។

៣. បើប្រសិនជា ភាគីមួយសង្កេតឃើញថាការផ្សំមានទាក់ទងទៅនឹងបទបញ្ញត្តិផ្សេងៗ នៃកថាខ័ណ្ឌពីមុនភាគីនោះ អាចសំរេចអោយការផ្សំរួចផុតពីវិធានការត្រួតពិនិត្យមួយ រឺទាំងអស់ដែលមានគ្រោងទុកក្នុងអនុសញ្ញានេះ ទោះជានៅក្នុងប្រទេសរបស់ខ្លួន រឺនៅក្នុងតំបន់មួយរបស់ភាគីខ្លួនក៏ដោយ។ យ៉ាងណាក៏ការផ្សំ ដូចបានពោលមកនេះត្រូវតែស្ថិតនៅក្រោមកាតព្វកិច្ចដូចមានក្នុងមាត្រាបន្ទាប់ទៅនេះ :

ក./ មាត្រា ៨ (អជ្ញាប័ណ្ណ)ដូចធ្លាប់អនុវត្តចំពោះការធ្វើ

ខ./ មាត្រា ១១ (ការចុះបញ្ជី) ដូចធ្លាប់អនុវត្តចំពោះការផ្សំដែលបានរួចផុតនានា

គ./ មាត្រា១៣ (ការហាមឃាត់ហើយ និងការកាត់បន្ថយការនាំចេញ និការនាំចូល)

ឃ./ មាត្រា១៥ (ការធ្វើអធិការកិច្ច) ដូចធ្លាប់អនុវត្តចំពោះការធ្វើ

ង./ មាត្រា១៦ (ពតមានដែលត្រូវផ្តល់ពីភាគីផ្សេងៗ) ដូចធ្លាប់អនុវត្តចំពោះការផ្សំដែលបានរួចចាកផុតនានា និង

ច./ មាត្រា២២ (បទបញ្ញត្តិព្រហ្មទណ្ឌ)ក្នុងករណីចាំបាច់បង្ក្រាបអំពើទាំងឡាយដែលផ្ទុយនឹងច្បាប់ រឺ បទបញ្ជាដែលអនុម័តដោយមិនអនុលោមតាមកាតព្វកិច្ចផ្សេងៗខាងលើ ។

ភាគីដូចបានជំរាបមកនេះ ត្រូវធ្វើលិខិតជូនដំណឹងទៅអគ្គលេខាធិការពីការសំរេចទាំងឡាយ ដូចជាឈ្មោះ និងសមាសធាតុនៃការផ្សំដែលបានរួចចាកផុត និងវិធានការត្រួតពិនិត្យដែលការផ្សំនោះ បានរួចចាកផុត ។ អគ្គលេខាធិការនឹងបញ្ជូនលិខិតជូនដំណឹងនេះទៅភាគីផ្សេងៗទៀត ទៅអង្គការសុខភាពពិភពលោក និងទៅក្រុមប្រឹក្សា។

៤. បើប្រសិនជាមានភាគីមួយ រឺមានអង្គការសុខភាពពិភពលោក មានពតិមានស្តីពីការផ្សំរួចចាកផុតតាមន័យកថាខ័ណ្ឌទី ៣ ដែលបើតាមយោបល់របស់ភាគី រឺរបស់អង្គការសុខភាពពិភពលោកនោះ ពតិមានទាំងនោះបានបញ្ជាក់ថាត្រូវលុបចោលទាំងស្រុង រឺក៏ផ្នែកខ្លះៗនៃការការអនុញ្ញាតអោយរួចចាកផុតចេញនោះ ភាគី រឺអង្គការសុខភាពពិភពលោកនោះត្រូវធ្វើលិខិតជូនលិខិតជូនដំណឹងពីពតិមានទាំងនោះ ទៅអគ្គលេខាធិ-ការ និងផ្តល់ពតិមានបន្ថែកផ្សេងៗ បញ្ជាក់ប្រាប់អគ្គលេខាធិការភ្ជាប់ជាមួយនឹងលិខិតជូនដំណឹងនោះ ។ អគ្គលេខាធិការនឹងបញ្ជូនលិខិតជូនដំណឹងនោះ ....ដោយមានភ្ជាប់ទៅជាមួយនូវពតិមានទាំងអស់ ដែលអគ្គលេខាធិការយល់ឃើញថា សមហេតុផលជូនទៅភាគី ជូនទៅគណៈកម្មការ និង នៅពេលដែលលិខិតជូន

ដំណឹងត្រូវបានធ្វើឡើងដោយភាគីមួយវិញនោះ គឺត្រូវបញ្ជូនទៅអង្គការសុខភាពពិភពលោក។ អង្គការសុខភាពពិភពលោក នឹងជូនដំណឹងទៅគណៈកម្មការលើការវាយតំលៃពីការផ្សំដោយយកចិត្តទុកដាក់ពីកត្តាផ្សេងៗ ដែលចែងនៅក្នុងកថាខ័ណ្ឌទី២ ព្រមទាំងពីអនុសាសន៍នៃវិធានការត្រួតពិនិត្យ ដែលការជូនសំណឹងនឹងមិនអនុញ្ញាត ឱ្យរួចផុតជាយថាហេតុទៀតឡើយ ។ ដោយគិតឃើញថា ដំណឹងដែលបានមកពីអង្គការសុខភាពពិភពលោក គណៈកម្មការដែលមានការវាយតំលៃនឹងមានលក្ខណៈច្បាស់លាស់ផ្នែកវេជ្ជសាស្ត្រ និងវិជ្ជាសាស្ត្រ និងដោយយក ចិត្តទុកដាក់ពីកត្តាខាងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច គតិយុត្ត រដ្ឋបាល និងកត្តាផ្សេងៗទៀតដែលគណៈកម្មការ យល់ឃើញថាសមហេតុផលនោះ គណៈកម្មការអាចសំរេច ដើម្បីបញ្ឈប់នូវការលើកលែងផុតពីវិធានការត្រួតពិនិត្យមួយ រឺ ទាំងអស់ទៀតហើយ ។ អគ្គលេខាធិការនឹងផ្តល់ដំណឹងពីសេចក្តីសំរេចទាំងអស់របស់គណៈកម្មការដែលបានធ្វើ តាមន័យនៃកថាខ័ណ្ឌនេះ ជូនទៅគ្រប់រដ្ឋសមាជិកនៃអង្គការសហប្រជាជាតិ ទៅរដ្ឋដែលមិនមែនជាភាគីសមាជិកនៃអនុសញ្ញានេះ ទៅអង្គការសុខភាពពិភពលោក ហើយនិងជូនទៅក្រុមប្រឹក្សា ។ គ្រប់ភាគីទាំងអស់ត្រូវចេញបទបញ្ញត្តិផ្សេងៗ ដើម្បីលុបចោលការអនុញ្ញាតឱ្យរួចផុតពីវិធានការត្រួតពិនិត្យមួយរឺច្រើនដូចមាននោះនៅក្នុងរយៈ ពេល១៨០ថ្ងៃ គិតពីកាលបរិច្ឆេទនៃការជូនដំណឹងរបស់អគ្គលេខាធិការ ។

មាត្រា៨ : បទបញ្ញត្តិពិសេសផ្សេងទៀតដែលទាក់ទងនឹងវិសាលភាពនៃការត្រួតពិនិត្យ

ចំពោះសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទផ្សេងទៀត ក្រៅពីសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទក្នុងតារាងទី ១ ភាគីអាច :

ក./ អនុញ្ញត្តិអោយយកតាមខ្លួនអ្នកដំណើរអន្តរជាតិ បរិមាណដ៏តិចតួច ចំពោះការផ្សំប្រើផ្ទាល់ខ្លួនភាគីនីមួយៗ អាចបញ្ជាក់ពេលនេះថា ការផ្សំទាំងនោះត្រូវបានទទួលការអនុញ្ញាតតាមច្បាប់រួចហើយ ។

ខ./ អនុញ្ញាតអោយប្រើសារធាតុទាំងនោះក្នុងឧស្សាហកម្ម សំរាប់ផលិតសារធាតុដែលមិនប៉ះពាល់ដល់ប្រពន្ធ័សរសៃប្រសាទ ឬ ផលិតផល តំរូវអោយមានវិធានការត្រួតពិនិត្យដោយអនុសញ្ញានេះ រហូតទាល់តែសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទទាំងនោះ ស្ថិតនៅតាមសភាពដែលគេមិនអាចយកវាទៅប្រើបំពាន រឺ ក៏ប្រមូលបាន និង

គ./ អនុញ្ញាតអោយប្រើសារធាតុទាំងនោះ ចំពោះតែបុគ្គលណាដែលមានការអនុញ្ញាតច្បាស់លាស់ពីអាជ្ញាធរមានសមត្ថកិច្ចក្នុងការប្រើសារធាតុដូចបានពោលនោះដើម្បីចាប់សត្វ តែដោយសារធាតុទាំងនោះត្រូវបានត្រួតពិនិត្យដោយវិធានការផ្សេងៗរបស់អនុសញ្ញានេះតែប៉ុណ្ណោះ ។

មាត្រា៥ : ការកំណត់ព្រំដែនប្រើក្នុងគោលដៅវេជ្ជសាស្ត្រនិងវិទ្យាសាស្ត្រ

១. ភាគីនីមួយៗត្រូវកំណត់ព្រំដែនប្រើសារធាតុតារាងទី ១ តាមការគ្រោងទុកក្នុងតារាង ៧ ។

២. លើកលែងតែមានចែងនៅក្នុងបទបញ្ញត្តិនៃមាត្រា ៤ ភាគីនីមួយៗត្រូវកំណត់ព្រំដែន តាមរយៈវិធានការដែលភាគីនីមួយៗយល់ឃើញថាសមស្របពីការធ្វើ ការនាំចេញ ការនាំចូល ការចែកចាយ ការស្តុកទុកពាណិជ្ជកម្ម ការប្រើប្រាស់ និងពីការរក្សាទុកសារធាតុនៃតារាងទី ១ ទី២ ទី៣ និងទី៤ ក្នុងគោលដៅផ្នែកវេជ្ជសាស្ត្រ និងផ្នែកវិទ្យាសាស្ត្រ ។

៣. ភាគីគួរណាស់តែកុំអនុញ្ញាតអោយមានការរក្សាទុកសារធាតុនៃតារាងទី២ ទី៣ ហើយនិង ទី៤ លើកលែងតែមានល័ក្ខខ័ណ្ឌផ្សេងៗបានគ្រោងទុកដោយច្បាប់រួចហើយ ។

មាត្រា៦ : រដ្ឋបាលពិសេស

ដើម្បីអនុវត្តបទបញ្ញត្តិនៃអនុសញ្ញានេះភាគីនីមួយៗគួរណាស់តែបង្កើត និង រក្សាអោយមានរដ្ឋបាលពិសេសមួយ ។ រដ្ឋបាលនេះមានប្រយោជន៍បើវាជារដ្ឋបាលពិសេស បង្កើតតាមន័យនៃបទបញ្ញត្តិអនុសញ្ញាផ្សេងៗដែលបានដាក់គ្រឿងញៀនក្រោមការត្រួតពិនិត្យ រឺ ក៏ជារដ្ឋបាលដែលសហការជិតស្និទ្ធជាមួយនឹងរដ្ឋបាលពិសេសនោះ ។

មាត្រា៧ : បទបញ្ញត្តិពិសេសចំពោះសារធាតុនៃតារាងទី ១

ចំពោះសារធាតុតារាងទី ១ ភាគីត្រូវតែ :

ក./ ហាមឃាត់រាល់ការប្រើសាធាតុអស់ទាំងនោះ លើកលែងតែប្រើក្នុងគោលដៅវិទ្យាសាស្ត្រ រឺវេជ្ជសាស្ត្រត្រឹមកំរិតដ៏តិចតួចបំផុត តាមរយៈបុគ្គលដែលមានការអនុញ្ញាតត្រឹមត្រូវធ្វើការនៅក្នុងគ្រឹះស្ថានវេជ្ជសាស្ត្រ រឺ វិទ្យាសាស្ត្រឡើងទៅរដ្ឋាភិបាលរបស់ខ្លួនដោយផ្ទាល់ រឺ បានអនុញ្ញាតដោយត្រឹមត្រូវពីរដ្ឋភិបាលរបស់ខ្លួនតែប៉ុណ្ណោះ

ខ./ តំរូវអោយការធ្វើពាណិជ្ជកម្ម ការចែកចាយ និង ការរក្សាទុកសារធាតុទាំងនោះ មានអាជ្ញាប័ណ្ណពិសេស រឺ មានការអនុញ្ញាតណាមួយជាមុនសិន

គ./ គ្រោងទុកការចាំឃ្លាំមើលដ៏តឹងរឹងជាមុនលើសកម្មភាព និង អំពើផ្សេងៗ ដូចមានចែងនៅក្នុងវគ្គ ក និង វគ្គ ខ

ឃ./ អនុញ្ញាតអោយប្រគល់ជូន ចំពោះតែបុគ្គលដែលមានការអនុញ្ញាតត្រឹមត្រូវតាមកំរិតបរិមាណចាំបាច់សំរាប់គោលដៅដូចដែលលិខិតអនុញ្ញាតបានយល់ព្រម;

ង./ តំរូវអោយបុគ្គលដែលអនុវត្តមុខងារខាងវេជ្ជសាស្ត្រ និង ខាងវិទ្យាសាស្ត្រ ចុះបញ្ជីពីលទ្ធកម្មនៃសារធាតុទាំងនេះ ហើយនិងពីការប្រើលំអិតសារធាតុទាំងនោះការចុះបញ្ជីនេះត្រូវបានរក្សាទុករអស់រយៈពេលយ៉ាងតិចបំផុតពីរឆ្នាំ បន្ទាប់ពីការប្រើចុងក្រោយត្រូវបានកត់ត្រាទុករួចហើយ និង

ច./ ហាមឃាត់មិនអោយមានការនាំចេញ និង ការនាំចូលសារធាតុទាំងនោះទេ លើកលែងតែអ្នកនាំចេញ និង អ្នកនាំចូលជាអាជ្ញាធរមានសមត្ថកិច្ច រឺជារដ្ឋបាលមានសមត្ថកិច្ចនៃប្រទេស រឺនៃតំបន់អ្នកនាំចេញ និង នាំចូលរៀងគ្នា រឺជាបុគ្គល រឺសហគ្រាសផ្សេងទៀត ដែលអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរឺតំបន់របស់ខ្លួនបានអនុញ្ញាតឱ្យត្រឹមត្រូវសំរាប់គោលដៅនេះ ។ ការតំរូវទាំងឡាយដូចមានចែងក្នុងកថាខ័ណ្ឌទី១ នៃមាត្រា ១២ ទាក់ទងនឹងការអនុញ្ញាតឱ្យនាំចេញ និងនាំចូលសារធាតុតារាង ២ ក៏អនុវត្តចំពោះសារសារធាតុនៃតារាងទី ១ បានដែរ ។

មាត្រា៨ : អាជ្ញាប័ណ្ណ

១. ភាគីនីមួយៗតំរូវអោយមានអាជ្ញាប័ណ្ណ រឺ ក៏វិធានការត្រួតពិនិត្យរបៀបគ្នានេះចំពោះការធ្វើពាណិជ្ជកម្ម (មានរួមទាំងពាណិជ្ជកម្មនាំចេញ និង នាំចូល) និង ការចែកចាយសារធាតុនៃតារាងទី២ ទី៣ និង ទី៤ ។

២. ភាគី :

ក./ នឹងធ្វើការចាំឃ្លាំមើលចំពោះបុគ្គល និងសហគ្រាសទាំងអស់ដែលបានអនុញ្ញាតអោយអនុវត្តដោយត្រឹមត្រូវការធ្វើពាណិជ្ជកម្ម (មានរួមទាំងពាណិជ្ជកម្មនាំចេញ និងនាំចូល) រឺក៏ការចែកចាយសារធាតុដូចមានចែងទុកក្នុងកថាខ័ណ្ឌទី១

ខ./ នឹងដាក់អោយមានរបបអាជ្ញាប័ណ្ណ រឺ វិធានការត្រួតពិនិត្យរបៀបផ្សេងទៀត ចំពោះគ្រឹះស្ថាន និង ទីកន្លែងដែលក្នុងនោះអាចមានការធ្វើនេះ ពាណិជ្ជកម្មនេះ រឺការចែកចាយនេះ និង

គ./ នឹងធ្វើយ៉ាងណាឱ្យវិធានការការពារសន្តិសុខចំពោះគ្រឹះស្ថាន និងទីកន្លែងទាំងនោះត្រូវតែមាន ដើម្បីការពារការលួច រឺ ការគេចបន្លំស្តុកផ្សេងដទៃទៀត ។

៣. បទបញ្ញត្តិនៃកថាខ័ណ្ឌទី១ និងទី២ នៃមាត្រានេះ ដែលទាក់ទងនឹងរបបមានអាជ្ញាប័ណ្ណ រឺ វិធានការត្រួតពិនិត្យរបៀបផ្លានេះ មិនចាំបាច់អនុវត្តចំពោះបុគ្គលដែលមានការអនុញ្ញាតត្រឹមត្រូវអោយធ្វើមុខងារខាងការព្យាបាល រឺខាងវិទ្យាសាស្ត្រ ហើយដែលកំពុងតែអនុវត្តមុខងារទាំងនោះ នោះទេ ។

៤. ភាគីត្រូវតំរូវអោយបុគ្គលទាំងអស់ដែលខ្លួនបានប្រគល់អជ្ញាប័ណ្ណ ដោយសារការអនុវត្តអនុសញ្ញានេះ រឺបុគ្គលដែលមានច្បាប់អនុញ្ញាតមានតំលៃសមមូលស្របតាមបទបញ្ញត្តិដូចបានចែងទុកក្នុងកថាខ័ណ្ឌទី១ នៃមាត្រានេះ រឺក្នុងវគ្គ ខ នៃមាត្រា៧ត្រូវតែមានលក្ខណៈសម្បត្តិត្រឹមត្រូវគ្រប់គ្រាន់ដើម្បីអនុវត្តអោយមានប្រសិទ្ធភាពនិងដោយស្មោះត្រង់នូវបទបញ្ញត្តិច្បាប់ និងបទបញ្ជាផ្សេងៗ ដែលបានអនុម័តពេលប្រតិបត្តិអនុសញ្ញានេះ។

មាត្រា៩ : វេជ្ជបញ្ជា

១. ភាគីនឹងតំរូវអោយសារធាតុនៃតារាងទី ទី២ ទី៣ និងទី៤ ទាំងនោះត្រូវផ្តល់ រឺចែកចាយប្រើចំពោះតែឯកជនណាដែលមានវេជ្ជបញ្ជាប៉ុណ្ណោះ លើកលែងតែករណីមានច្បាប់អនុញ្ញាតត្រឹមត្រូវអោយឯកជនអាចមាន អាចប្រើប្រាស់ អាចចែកចាយប្រើ រឺ ធ្វើរដ្ឋបាលសារធាតុទាំងនោះ នៅក្នុងការអនុវត្តមុខងារខាងការព្យាបាល រឺខាងវិទ្យាសាស្ត្រតែប៉ុណ្ណោះ ។

២. ភាគីត្រូវចាត់វិធានការចាំបាច់នានា ដើម្បីអោយវេជ្ជបញ្ជាដែលមានដាក់សារធាតុរបស់តារាងទី២ ទី៣ និង ទី៤ ត្រូវបានចេញជូនស្របតាមការប្រតិបត្តិនៃវិជ្ជាពេទ្យ និងត្រូវបានដាក់អោយស្ថិតនៅក្រោមបទបញ្ជាការពារសុខភាព និងបទបញ្ជាការពារផលប្រយោជន៏សារធារណៈ ជាអាទិ៍ចំពោះចំនួនដងដែលអាចប្រើវេជ្ជបញ្ជាឡើងវិញបាន និងរយៈពេលសុពលភាពនៃវេជ្ជបញ្ជានោះ ។

៣. ទោះជាមានបទបញ្ញត្តិនៃកថាខ័ណ្ឌ ១ ក៏ដោយតាមយោបល់របស់ខ្លួនបើស្ថានភាពនៅមូលដ្ឋានតំរូវ និងក្នុងល័ក្ខខ័ណ្ឌដែលភាគីអាចចេញវេជ្ជបញ្ជា មាន្នរួមទាំងការចុះបញ្ជីការផងនោះភាគីអាចអនុញ្ញាតអោយឱសថការីដែលមានអាជ្ញាប័ណ្ណ រឺគ្រប់អ្នកចែកចាយរាយផ្សេងទៀតទាំងអស់ដែលមានអាជ្ញាប័ណ្ណ ហើយដែល

បានទទួលការតែងតាំងពីអាជ្ញាធរទទួលបន្ទុកខាងសុខភាពសាធារណៈនៅក្នុងប្រទេស រឺ នៅក្នុងមួយផ្នែក នៃប្រទេសរបស់ខ្លួន អោយផ្តល់តាមឆន្ទានុសិទ្ធិរបស់ឱសថការី រឺរបស់អ្នកចែកចាយទាំងនោះ ដោយគ្មាន វេជ្ជបញ្ជាជូនទៅឯកជនប្រើប្រាស់នៅក្នុងករណីពិសេស និងក្នុងគោលបំណងវេជ្ជសាស្ត្រ ចំពោះសារធាតុ តារាងទី៣ និងទី៤ នៅបរិមាណតិចតួចតាមកំរិតកំណត់ដែលភាគី នឹងត្រូវបញ្ជាក់ច្បាស់លាស់ ។

មាត្រា១០ : ការព្រមានរំលឹកពីការវេចខ្ចប់ទំនិញ និងការប្រកាសផ្សាយពាណិជ្ជកម្ម

១. ដោយយកចិត្តទុកដាក់ដល់បទបញ្ជា រឺ អនុសាសន៍ដែលពាក់ព័ន្ធផ្សេងៗរបស់អង្គការសុខភាពពិភព លោកដែលតាមយោបល់របស់អង្គការនេះ ភាគីនីមួយៗត្រូវមានបញ្ជាក់នៅលើស្លាកសញ្ញា កាលបើមាន លទ្ធភាពធ្វើហើយនិងតាមចម្លតាលើនិវេទន៍ដែលភ្ជាប់មកជាមួយនឹងការខ្ចប់ទំនិញ ចំពោះការចែកចាយរាយ សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទពីរបៀបប្រើព្រមទាំងពីការប្រុងប្រយ័ត្នដែលត្រូវមាន និង ការដែល ត្រូវព្រមានរំលឹកចាំបាច់ផ្សេងៗ ដើម្បីរក្សាសុវត្ថិភាពចំពោះអ្នកប្រើប្រាស់ ។

២. ដោយគិតអោយបានត្រឹមត្រូវពីបទបញ្ញត្តិច្បាប់រដ្ឋធម្មនុញ្ញប្រទេសរបស់ខ្លួន ភាគីនីមួយៗត្រូវហាម ឃាត់រាល់ការផ្សាយពាណិជ្ជកម្មផ្សេងៗ ដែលមានការពាក់ព័ន្ធនឹងសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និងដែលផ្តោតលើសាធារណៈជនដ៏ច្រើនកុះករនោះ ។

មាត្រា១១ : ការចុះបញ្ជី

១. ចំពោះសារធាតុនៃតារាងទី១ ភាគីត្រូវតំរូវអោយអ្នកធ្វើសារធាតុ និងបុគ្គលដទៃទៀតទាំងអស់ ដែលមានការអនុញ្ញាតអោយធ្វើពាណិជ្ជកម្ម និង ចែកចាយសារធាតុនេះតាមមាត្រា ៧ ត្រូវចាត់នីតិវិធី ត្រូវមានការចុះបញ្ជីតាមល័ក្ខខ័ណ្ឌកំណត់ដោយភាគីនីមួយៗ ដោយបញ្ជាក់អោយច្បាស់ពីបរិមាណសារធាតុ ដែលបានធ្វើរួចហើយ បរិមាណដែលបានរក្សាទុកក្នុងស្តុក និង សំរាប់លទ្ធកម្មនីមួយៗ និងការចំណាយ នីមួយៗដែរ ដោយលំអិតពីបរិមាណ កាលបរិច្ឆេទ និងឈ្មោះអ្នកផ្តល់ និង អ្នកទទួល ។

២. ចំពោះសារធាតុនៃតារាងទី២ និងទី៣ ភាគីត្រូវតំរូវអោយអ្នកធ្វើសារធាតុ អ្នកចែកចាយដុំ អ្នកនាំចេញ និងអ្នកនាំចូល ចាត់នីតិវិធីអោយមានការចុះបញ្ជីតាមល័ក្ខខ័ណ្ឌកំណត់ដោយភាគីនីមួយៗ ដោយ បញ្ជាក់ច្បាស់ពីបរិមាណសារធាតុដែលបានធ្វើហើយក៏ដូចជាចំពោះលទ្ធកម្មនីមួយៗ និងចំពោះការចំណាយ នីមួយៗដែរ ពីបរិមាណកាលបរិច្ឆេទ និងឈ្មោះនៃអ្នកផ្តល់ និងអ្នកទទួល ។

៣. ចំពោះសារធាតុនៃតារាងទី២ ភាគីនឹងតំរូវអោយអ្នកចែកចាយរាយអោយគ្រឹះស្ថានពាក់ព័ន្ធជាមួយ នឹង មន្ទីរពេទ្យ អោយមជ្ឈមណ្ឌលព្យាបាល និងស្ថាប័នវិទ្យាសាស្ត្រផ្សេងៗ ចាត់នីតិវិធីអោយមានការចុះបញ្ជីតាមល័ក្ខខ័ណ្ឌកំណត់ដោយភាគីនីមួយៗ ដោយបញ្ជាក់ច្បាស់ពីបរិមាណកាលបរិច្ឆេទ និងឈ្មោះអ្នកផ្តល់ និងអ្នកទទួលចំពោះលទ្ធកម្មនីមួយៗ និងចំពោះអនុបទាននីមួយៗ ។

៤. ដោយប្រើវិធីសមស្រប និងដោយគិតដល់ការប្រតិបត្តិខាងវិជ្ជាជីវៈ និងខាងពាណិជ្ជកម្មផ្ទាល់របស់ភាគី ភាគីត្រូវធានាថា ពត៌មានដែលមានទាក់ទងនឹងលទ្ធកម្ម និងអនុប្បទានសារធាតុនៃតារាងទី៣ របស់អ្នកចែកចាយរាយ ពីសំណាក់គ្រឹះស្ថានពាក់ព័ន្ធជាមួយនឹងមន្ទីរពេទ្យ មជ្ឈមណ្ឌលព្យាបាលនិងរបស់ស្ថាប័នវិទ្យាសាស្ត្រផ្សេងៗអាចត្រូវបានគេសាកសួរពិគ្រោះបានដោយស្រួល ។

៥. ចំពោះសារធាតុនៃតារាងទី៤ ភាគីត្រូវតំរូវអោយ អ្នកធ្វើសារធាតុ អ្នកនាំចេញ និង អ្នកនាំចូល ចាត់នីតិវិធីអោយមានការចុះបញ្ជីតាមល័ក្ខខ័ណ្ឌកំណត់ដោយភាគីនីមួយៗ ដោយបញ្ជាក់ពីបរិមាណសារធាតុ ដែលបានធ្វើបាននាំចេញ និងបានបាននាំចូលរួចហើយ ។

៦. ភាគីត្រូវតំរូវអោយអ្នកធ្វើការផ្សំរួចផុតពីការត្រួតពិនិត្យស្របតាមកថាខ័ណ្ឌ ៣ នៃមាត្រា៣ ចុះបញ្ជីនូវបរិមាណនៃសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទនីមួយៗ ដែលយកមកប្រើក្នុងការធ្វើការផ្សំរួចផុតនីមួយៗ នូវប្រភេទ និង នូវបរិមាណសរុបនៃការផ្សំរួចផុតនោះដែលធ្វើចេញពីសារធាតុមួយនោះ ក៏ដូចជានិទ្ទេស ដែលពាក់ព័ន្ធនឹងអនុប្បទានលើកទី១ នៃការផ្សំដូចបានជំរាបមកហើយនោះ ។

៧. ភាគីត្រូវធានាថា របាយការណ៍ និង ពត៌មានដូចមានចែងក្នុងមាត្រានេះហើយដែលចាំបាច់សំរាប់ការរៀបចំរបាយការណ៍ដូចដែលបានគ្រោងទុកនៅក្នុងមាត្រា ១៦ ត្រូវបានគេរក្សាទុកក្នុងរយៈពេលពីរឆ្នាំយ៉ាងតិច ។

មាត្រា ១២ : បទបញ្ញត្តិពាក់ព័ន្ធនឹងពាណិជ្ជកម្មអន្តរជាតិ

១. ក/ រាល់ភាគីដែលអនុញ្ញាតច្បាប់អោយនាំចេញ រឺ អោយនាំចូលសារធាតុនៃតារាងទី១ រឺ ទី២ ត្រូវតំរូវអោយមានលិខិតអនុញ្ញាតអោយនាំចូលវិញ សំរាប់ការនាំចេញ រឺអោយនាំចេញវិញ សំរាប់ការនាំចូល ដាច់ដោយឡែកពីគ្នា ដែលគាត់តែងតាមរូបមន្តគំរូ រៀបចំឡើងដោយគណៈកម្មការ ទោះបីជាសារធាតុមួយ រឺក៏សារធាតុច្រើនក៏ដោយ ។

ខ./ លិខិតអនុញ្ញាតនេះ ត្រូវមាននាមករណ៍សារធារណៈ មានលក្ខណៈអន្តរជាតិរបស់សារធាតុ រឺបើគ្មាននាមករណ៍បែបនេះទេ ត្រូវកំណត់យកឈ្មោះសារធាតុនៅក្នុងតារាង ត្រូវមានបរិមាណដែលត្រូវនាំចេញ រឺ ដែលត្រូវនាំចូលសណ្ឋានឱសថកម្មសារធាតុ ឈ្មោះនិងអាសយដ្ឋាននៃអ្នកនាំចេញ និងអ្នកនាំចូល និងរយៈពេលធ្វើការនាំចេញ រឺការនាំចូល ។ បើប្រសិនជាសារធាតុនាំចេញ រឺ នាំចូលមានសណ្ឋានជាការផ្សំ ឈ្មោះនៃការផ្សំ បើប្រសិជាមានក៏ត្រូវបញ្ជាក់ដែរ ។ លិខិតអនុញ្ញាតអោយនាំចេញ ត្រូវបញ្ជាក់ផងដែរពីលេខ និង ពីកាលបរិច្ឆេទនៃវិញ្ញាបនប័ត្រនាំចូល និង បញ្ជាក់ឱ្យបានច្បាស់អាជ្ញាធរដែលបានចេញវិញ្ញាបនប័ត្រនាំចេញនេះ ។

គ./ មុននឹងចេញលិខិតអនុញ្ញាតអោយនាំចេញ ភាគីត្រូវតំរូវអោយមានលិខិតអនុញ្ញាតអោយនាំចូលដែលចេញអោយដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេស រឺនៃតំបន់អ្នកនាំចូល ដោយមានបញ្ជាក់ថាការនាំចូលសារធាតុមួយ រឺសារធាតុច្រើនដែលត្រូវការនោះត្រូវបានយល់ព្រម ហើយលិខិតអនុញ្ញាតអោយនាំចូលនេះ ត្រូវបានរៀបចំឡើងដោយបុគ្គល រឺគ្រឹះស្ថានដែលស្នើសុំអនុញ្ញាតនាំចេញ ។

ឃ./ សេចក្តីចម្លងនៃលិខិតអនុញ្ញាតអោយនាំចេញ ត្រូវភ្ជាប់មកជាមួយការផ្ញើនីមួយៗ ហើយរដ្ឋាភិបាលដែលចេញលិខិតអនុញ្ញាតអោយនាំចេញ ត្រូវផ្ញើជូនសេចក្តីចម្លងលិខិតអនុញ្ញាតនេះ មួយច្បាប់ទៅរដ្ឋាភិបាលនៃប្រទេស រឺនៃតំបន់អ្នកនាំចូល ។

ង./ កាលបើការនាំចូលត្រូវបានអនុវត្តរួចហើយ រដ្ឋាភិបាលនៃប្រទេស រឺតំបន់អ្នកនាំចូល ត្រូវផ្ញើត្រលប់ទៅរដ្ឋាភិបាលនៃប្រទេស រឺនៃតំបន់អ្នកនាំចេញវិញ នូវលិខិតអនុញ្ញាតនាំចេញនោះ ដោយមានសេចក្តីបញ្ជាក់ អះអាងពីបរិមាណដែលបាននាំចូលពិតប្រាកដ។

២. ក./ ចំពោះការនាំចេញសារធាតុនៃតារាងទី៣នីមួយៗ ភាគីត្រូវតំរូវអោយអ្នកនាំចេញរៀបចំប្រតិវេទន៍មួយមានបីច្បាប់ តាក់តែងតាមរូបមន្តគំរូដែលរៀបចំឡើងដោយគណៈកម្មការ មានដាក់ដំណឹងការអោយការណ៍ដូចតទៅ :

i/ ឈ្មោះ និងអាស័យដ្ឋាននៃអ្នកនាំចេញ និងនៃអ្នកនាំចូល

ii/ នាមករណ៍សារធារណៈ មានលក្ខណៈអន្តរជាតិ រឺបើគ្មាននាមករណ៍បែបនេះទេ ត្រូវកំណត់យកឈ្មោះ សារធាតុនៅក្នុងតារាង ;

iii/ បរិមាណនៃសារធាតុ និងសណ្ឋាននៃឱសថកម្ម ដែលនៅក្នុងសណ្ឋាននោះសារធាតុត្រូវបាននាំចេញ ហើយបើប្រសិនជាមានសណ្ឋានជាការផ្សំវិញនោះ ត្រូវមានឈ្មោះការផ្សំនោះបើប្រសិនជាមាន និង

iv/ កាលបរិច្ឆេទផ្ញើ ។

ខ./ អ្នកនាំចេញ ត្រូវផ្តល់ជូនទៅអាជ្ញាធរមានសមត្ថកិច្ច នៃប្រទេសរបស់ខ្លួន រឺនៃតំបន់របស់ខ្លួន នូវប្រតិវេទន៍នេះជាពីរច្បាប់ ។រីឯច្បាប់ទី ៣ អ្នកនាំចេញត្រូវភ្ជាប់តាមការផ្ញើរបស់ខ្លួន ។

គ./ ភាគីនៃទឹកដីដែលមានសារធាតុនៃតារាងទី៣ត្រូវបាននាំចេញ ត្រូវតែបញ្ជូនភ្លាមតាមដែលអាចធ្វើបាន យឺតបំផុតចំនួនកៅសិបថ្ងៃ ក្រោយពីកាលបរិច្ឆេទផ្ញើទៅអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេស រឺ នៃតំបន់អ្នកនាំចូល ជាសំបុត្ររអនុសិទ្ធិដែលមានបញ្ជាក់ត្រឡប់វិញថា.បានទទួលប្រទិវេទន៍មួយច្បាប់ពីអ្នកនាំចេញ ។

ឃ./ ចាប់តាំងពីបានទទួលកញ្ចប់មក ភាគីអាចតំរូវឱ្យអ្នកនាំចូលផ្ញើជូនទៅអាជ្ញាធរមានសមត្ថកិច្ច នៃប្រទេសរបស់ខ្លួន រឺនៃតំបន់របស់ខ្លួននូវច្បាប់ដែលអមជាមួយការផ្ញើដោយមានចារខ្ទង់ត្រឹមត្រូវបញ្ជាក់ពីបរិមាណដែលបានទទួលនិងកាលបរិច្ឆេទទទួល ។

៣. ម្យ៉ាងទៀតសារធាតុនៃតារាង ទី១ និង ទី២ ត្រូវគោរពតាមបទបញ្ញត្តិដូចតទៅនេះ :

ក./ នៅក្នុងផែរូចពន្ធ និង តំបន់រួចពន្ធផ្សេងៗ ភាគីត្រូវចាំត្រួតត្រាមើល នឹងត្រួតពិនិត្យដូចជានៅតាមទីកន្លែងដទៃទៀត នៃទឹកដីរបស់ខ្លួនដែរ ទោះជាយ៉ាងណាក៏ដោយ ភាគីអាចអនុវត្តវិធានការ យ៉ាងខ្លាំងខ្លាជាងពីមុនបាន។

ខ./ ការនាំចេញមានទំរង់ជាការផ្ញើទៅធានាគារមួយចូលក្នុងគណនីសំរាប់បុគ្គលម្នាក់ ដែលមិនមែនជាបុគ្គលមានឈ្មោះនៅក្នុងលិខិតអនុញ្ញាតអោយនាំចេញ រឺក៏ផ្ញើទៅដាក់ប្រអប់ប្រៃសណីយ៍ត្រូវហាមឃាត់ ។

គ./ ការនាំចេញសារធាតុតារាងទី១ ដែលមានទំរង់ជាការផ្ញើទុកក្នុងឃ្លាំងមួយរបស់គយត្រូវហាមឃាត់ ។ ការនាំចេញសារធាតុតារាងទី២ដែលមានទំរង់ការផ្ញើទុកក្នុងឃ្លាំងមួយរបស់គយត្រូវហាមឃាត់ លើកលែងតែរដ្ឋាភិបាលនៃប្រទេសនាំចូល បញ្ជាក់នៅលើវិញ្ញាបនប័ត្រនាំចូលដែលរៀបចំឡើងដោយបុគ្គល រឺគ្រឹះស្ថាន ដែលសុំលិខិតអនុញ្ញាតនាំចេញ ដែលរដ្ឋាភិបាលនោះបានយល់ព្រមអោយនាំចូលតាមការផ្ញើក្នុងបំណងធ្វើការនាំចូលតាមការផ្ញើនោះយកមកទុកក្នុងឃ្លាំងរបស់គយមួយប៉ុណ្ណោះ ។ ក្នុងករណីបែបនេះការអនុញ្ញាតអោយនាំចេញ ត្រូវបញ្ជាក់ការផ្ញើត្រូវធ្វើក្នុងគោលដៅនេះ។ រាល់ការយកចេញពីឃ្លាំងគយត្រូវមានប័ណ្ណអនុញ្ញាតដែលចេញអោយ ដោយអាជ្ញាធរដែលមានឃ្លាំងនោះជាចំណុះខ្លួន ហើយក្នុងករណីដែលការផ្ញើមានកន្លែងទទួលនៅឯបរទេស ការផ្ញើត្រូវចាត់ទុកជាការនាំចេញមួយថ្មីទៀត តាមន័យនៃអនុសញ្ញានេះ ។

ឃ./ ការផ្ញើដែលចូលមកដល់ទឹកដីនៃភាគីមួយ រឺដែលចេញពីទឹកដីគ្មានអមមកជាមួយនូវលិខិតអនុញ្ញាត អោយនាំចេញត្រូវតែឃាត់ទុកដោយអាជ្ញាធរមានសមត្ថកិច្ច ។

ង./ ភាគីមួយ មិនត្រូវអនុញ្ញាតអោយមានការឆ្លងកាត់ទឹកដីរបស់ខ្លួន ទៅកាន់ប្រទេសមួយទៀតបានទេ ចំពោះការផ្ញើណាមួយក៏ដោយនៃសារធាតុទាំងនោះទោះជាការផ្ញើត្រូវផ្ទេរ រឺ ក៏មិនផ្ទេរពីមធ្យោបាយដឹកដឹកជញ្ជូន ដែលដឹកជញ្ជូនការផ្ញើនេះក៏ដោយ លើកលែងតែបានបង្ហាញសេចក្ដីចំលងលិខិតអនុញ្ញាតអោយនាំចេញចំពោះការផ្ញើនោះជូនដល់អាជ្ញាធរមានសមត្ថកិច្ចនៃភាគីដូចបានជំរាបជូនខាងលើ ។

ច./ អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសមួយ រឺ តំបន់មួយ ដែលអនុញ្ញាតអោយឆ្លងកាត់ការផ្ញើសារធាតុអស់នោះ ត្រូវតែចាត់វាលវិធានការចាំបាច់ផ្សេងៗទាំងអស់ ដើម្បីទប់ស្កាត់ការបង្វែងដាននូវការផ្ញើដូចបានពោលមកនេះទៅកាន់ទីកន្លែងមួយផ្សេងទៀត ក្រៅពីកន្លែងទទួល ដូចមានចុះក្នុងសេចក្ដីចម្លងលិខិតអនុញ្ញាតដែលមានភ្ជាប់មកជាមួយនឹងការផ្ញើនោះ លើកលែងតែរដ្ឋាភិបាលនៃប្រទេស រឺតំបន់ដែលមានការផ្ញើឆ្លងកាត់នោះអនុញ្ញាតអោយមានការឆ្លងកាត់ ត្រូវធ្វើពាក្យស្នើសុំវង្វែងដាន ដូចករណីធ្វើការសុំនាំចេញពីប្រទេស រឺ តំបន់ឆ្លងកាត់ ទៅកាន់ប្រទេសរឺ តំបន់ជាកន្លែងទទួលថ្មីដែរ ។ បើប្រសិនការបង្វែងដាន ត្រូវបានអនុញ្ញាតបទបញ្ញត្តិនៃវគ្គ ង របស់កថាខ័ណ្ឌទី១ ក៏អនុវត្តបានដែរ ចំពោះប្រទេស រឺ តំបន់ឆ្លងកាត់ជាមួយនឹងប្រទេសរឺតំបន់ដែលមានការផ្ញើនាំចេញតាំងពីដំបូងមក ។

ឆ./ គ្មានការផ្ញើនៃសារធាតុទាំងនេះណា ដែលឆ្លងកាត់ រឺដែលតំកល់ទុកក្នុងឃ្លាំងគយ អាចយកមកធ្វើការកែច្នៃណាមួយ ដែលនាំអោយកែប្រែធម្មជាតិរបស់សារធាតុបានឡើយ ។ សំបកវេចខ្ចប់មិនអាចកែប្រែដោយគ្មានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចបានទេ ។

ជ./.បើប្រសិនជាការផ្ញើត្រូវបានដឹកជញ្ជូនតាមផ្លូវអាកាស បទបញ្ញត្តិពីវគ្គ ង ដល់វគ្គ ឆ ពាក់ពន្ធ័នឹងការឆ្លងកាត់នៃសារធាតុនៅលើទឹកដីនៃភាគីមួយ មិនអាចអនុវត្តបាន តែក្នុងល័ក្ខខ័ណ្ឌដែលយន្តហោះ មិនចុះចតនៅក្នុងប្រទេសរឺតំបន់ឆ្លងកាត់នោះ ។ បើប្រសិនជាយន្តហោះចុះចតនៅក្នុងប្រទេស រឺ តំបន់នោះបទបញ្ញត្តិទាំងនោះ នឹងអនុវត្តបានក្នុងល័ក្ខខ័ណ្ឌដែលសភាពការណ៍តំរូវ ។

ឈ./ បទបញ្ញត្តិនៃកថាខ័ណ្ឌនេះ មិនលំអៀងដល់បទបញ្ញត្តិនៃកិច្ចព្រមព្រៀងអន្តរជាតិទាំងអស់ដែលកំណត់ព្រំដែនត្រួតពិនិត្យនោះទេ គឺអាចអនុវត្តបានចំពោះគ្រប់ភាគីទាំងអស់លើសារធាតុឆ្លងកាត់ទាំងនោះ ។

មាត្រា១៣ : ការហាមឃាត់ និងការកាត់បន្ថយការនាំចេញ និងការនាំចូល

១. ភាគីមួយអាចធ្វើលិខិតជូនដំណឹងទៅគ្រប់ភាគីផ្សេងទៀតតាមរយៈអគ្គលេខាធិការថា ភាគីខ្លួនហាមឃាត់ការនាំចូលមកក្នុងប្រទេសរបស់ខ្លួន រឺ មកក្នុងតំបន់ណាមួយរបស់ប្រទេសខ្លួនចំពោះសារធាតុមួយ រឺច្រើនប្រភេទនៃតារាងទី ២ ទី៣ រឺ ទី៤ ដូចដែលមានបញ្ជាក់លំអិតល្អន់ ក្នុងលិខិតជូនដំណឹងនោះ ។ នៅក្នុងលិខិតជូនដំណឹងនោះ ភាគីត្រូវប្រាប់ឈ្មោះសារធាតុក្នុងតារាងទី២ ទី៣ រឺ ទី៤ នោះ ។

២. បើប្រសិនជាភាគីមួយបានទទួលលិខិតជូនដំណឹង ស្តីពីការហាមឃាត់ដូចបានគ្រោងទុកក្នុងកថាខ័ណ្ឌទី១នេះ ភាគីនោះត្រូវចាត់វិធានការចាំបាច់នានា ដើម្បីកុំឱ្យសារធាតុបញ្ជាក់ក្នុងលិខិតជូនដំណឹងនោះត្រូវបាននាំចេញទៅប្រទេសរឺតំបន់ណាមួយនៃភាគីដែលធ្វើលិខិតជូនដំណឹងនោះអោយសោះ ។

៣. ទោះជាមានបទបញ្ញត្តិនៃកថាខ័ណ្ឌពីមុនៗរួចមកហើយក៏ដោយ ភាគីដែលបានធ្វើលិខិតជូនដំណឹងស្របតាមកថាខ័ណ្ឌទី១ អាចអនុញ្ញាតឱ្យនាំចូលក្នុងបរិមាណកំណត់ច្បាស់សារធាតុដែលត្រូវការ រឺការផ្សំដែលមានសារធាតុទាំងនោះដោយផ្តល់ប័ណ្ណអនុញ្ញាតអោយនាំចូលពិសេសក្នុងករណីនីមួយៗ។ អាជ្ញាធរនៃប្រទេសនាំចូលដែលបានផ្តល់អាជ្ញាប័ណ្ណអនុញ្ញាតឱ្យនាំចូលពិសេសត្រូវផ្ញើប័ណ្ណនេះពីរច្បាប់មានដាក់ឈ្មោះអាស័យដ្ឋានអ្នកនាំចូល និងអ្នកនាំចេញជូនទៅអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរឺតំបន់នាំចេញ ដែលគេអាចអនុញ្ញាតអោយអ្នកនាំចេញជូនទៅអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេស រឺ តំបន់នាំចេញដែលគេអាចអនុញ្ញាតអោយអ្នកនាំចេញធ្វើការផ្ញើអ៊ីវ៉ាន់ពេលនោះបាន ។ អីវ៉ាន់ផ្ញើនេះត្រូវមានភ្ជាប់មកជាមួយនូវប័ណ្ណអនុញ្ញាតអោយនាំចូលពិសេសមួយច្បាប់ ដោយមានចុះទិដ្ឋាការពីលើត្រឹមត្រូវពីអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេស រឺនៃតំបន់អ្នកនាំចេញ។

មាត្រា១៤ : បទបញ្ញត្តិពិសេស ដែលទាក់ទងទៅនឹងការដឹកជញ្ជូនសារធាតុដែលធ្វើអោយប៉ះពាល់ប្រព័ន្ធសរសៃប្រសាទដោយទុកក្នុងប្រអប់ជំនួយសង្គ្រោះបន្ទាន់របស់នាវាយន្តហោះ រឺ មធ្យោបាយដឹកជញ្ជូនសារធារណៈផ្សេងៗទៀត ដែលកំពុងចរាចរណ៍ផ្លូវអន្តរជាតិ

១. ការដឹកជញ្ជូនមានលក្ខណៈអន្តរជាតិតាមនាវា យន្តហោះ រឺ មធ្យោបាយដឹកជញ្ជូនសាធារណៈអន្តរជាតិផ្សេងៗ ដូចជារថភ្លើងក្រោមដី និងរថយន្តដឹកអ្នកដំណើរអន្តរជាតិនូវបរិមាណសារធាតុនៃតារាង

ទី២ ទី៣ រឺ ទី៤ ក៏រិតតិចតួច ក្នុងពេលធ្វើដំណើរសំរាប់ទុកចាក់ លេប ក្នុងការសង្គ្រោះបន្ទាន់ និងក្នុងករណីបន្ទាន់ផ្សេងៗនោះ មិនចាត់ទុកថាជាការនាំចេញ នាំចូល រឺ ការឆ្លងកាត់ទេ តាមន័យនៃអនុសញ្ញានេះ ។

២. ប្រទេសដែលមានការចុះបញ្ជីយានយន្តទាំងនោះត្រូវតែប្រុងប្រយ័ត្នអោយបានសមស្រប ដើម្បីទប់ស្កាត់ការប្រើប្រាស់មិនត្រឹមត្រូវនូវសារធាតុដែលចែងក្នុងកថាខ័ណ្ឌទី១ រឺ ការបង្វែងដានក្នុងគោលដៅខុសច្បាប់ ។ គណៈកម្មការ ត្រូវធ្វើអនុសាសន៍ពីការប្រុងប្រយ័ត្នទាំងនេះ ដោយសួរយោបល់អង្គការអន្តរជាតិមានសមត្ថកិច្ចផ្សេងៗ ។

៣. សារធាតុដែលដឹកជញ្ជូនតាម នាវា យន្តហោះ ឬ តាមមធ្យោបាយដឹកជញ្ជូនសាធារណៈអន្តរជាតិផ្សេងៗដូចជា រថភ្លើងក្រោមដី និង រថយន្តដឹកអ្នកដំណើរអន្តរជាតិ ស្របតាមបទបញ្ញត្តិនៃកថាខ័ណ្ឌ១នេះ ត្រូវតែស្ថិត នៅក្រោមច្បាប់ បទបញ្ជា ប័ណ្ណអនុញ្ញាត និងអាជ្ញាប័ណ្ណរបស់ប្រទេសដែលមានការចុះបញ្ជី ដោយមិន លំអៀងដល់សិទ្ធិរបស់អាជ្ញាធរមានសមត្ថកិច្ចមូលដ្ឋានផ្សេងៗ ដែលចាត់នីតិវិធីផ្ទៀងផ្ទាត់ ធ្វើអធិការកិច្ច និងធ្វើប្រតិបត្តិការ ត្រួតពិនិត្យនៅលើមធ្យោបាយដឹកជញ្ជូនទាំងនោះទេ ។ ការបញ្ចូលសារធាតុទាំងនោះ
ទៅក្នុងសរីរាង្គក្នុងករណីបន្ទាន់មិនត្រូវចាត់ទុកថាជាការប្រព្រឹត្តផ្ទុយនឹងបទបញ្ញត្តិនៃកថាខ័ណ្ឌទី១ នៃមាត្រាទី៩ នេះទេ ។

មាត្រា១៥ : អធិការកិច្ច

ភាគីត្រូវកសាងប្រព័ន្ធអធិការកិច្ច ចំពោះអ្នកធ្វើសារធាតុ អ្នកនាំចេញ អ្នកនាំចូល និងអ្នកចែកចាយដុំ និងរាយសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ព្រមទាំងចំពោះស្ថាប័នវេជ្ជសាស្ត្រ និង វិទ្យាសាស្ត្រដែលប្រើប្រាស់សារធាតុទាំងនោះ ។ ភាគីត្រូវគ្រោងទុកពីការធ្វើអធិការកិច្ចនេះឱ្យបានញឹកញាប់ដូចដែលភាគីយើងថាចាំបាច់ ចំពោះទីកន្លែងស្តុក និងចំពោះការចុះបញ្ជី ។

មាត្រា១៦ : របាយការណ៍ដែលត្រូវផ្តល់ពីភាគី

១. ភាគីត្រូវផ្តល់ជូនទៅអគ្គលេខាធិការនូវពត៌មានដែលគណៈកម្មការស្នើសុំ ក្នុងករណីចាំបាច់សំរាប់អនុវត្តន៍មុខងាររបស់គណៈកម្មការ ហើយជាអាទិ៍ របាយការណ៍ប្រចាំឆ្នាំដែលទាក់ទងទៅនឹងដំណើរប្រព្រឹត្តទៅនៃអនុសញ្ញាលើទឹកដីរបស់ភាគីរៀងៗខ្លួន រួមទាំងពត៌មានពី :

ក./ ការកែប្រែសំខាន់ៗដែលមានចំពោះច្បាប់ និងបទបញ្ញារបស់ខ្លួន ពាក់ព័ន្ធនឹងសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និង

ខ./ ជាពិសេសហេតុការណ៍ច្បាស់លាស់ បានលេចឡើងនៅលើទឹកដីរបស់ខ្លួន ទាក់ទងនឹងការប្រើបំពាន និងការចរាចរខុសច្បាប់នូវសារធាតុដែលប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ។

២. ម្យ៉ាងទៀត ភាគីត្រូវ ជូនដំណឹងទៅអគ្គលេខាធិការ ពីឈ្មោះ និង អាស័យដ្ឋាននៃអាជ្ញាធររដ្ឋាភិបាលដូចចែងក្នុងវគ្គ ច ចាប់ពីមាត្រា៧ ដល់មាត្រា១២ និងត្រង់កថាខ័ណ្ឌ៣ នៃមាត្រា ១៣ ។ អគ្គលេខាធិការនឹងផ្សព្វផ្សាយពត៌មានទាំងនោះទៅគ្រប់ភាគីទាំងអស់ ។

៣. ភាគីត្រូវផ្ញើជូនទៅអគ្គលេខាធិការនៅក្នុងរយៈពេលដ៏ឆាប់បំផុតពីរបាយការណ៍មួយ ស្តីពីការចរាចរខុសច្បាប់នូវសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និងពីការឃាត់ទុកសារធាតុដែលធ្វើចរាចរខុសច្បាប់នោះ កាលបើករណីទាំងនោះលេចចេញមកមានសារសំខាន់ដល់ភាគីទាំងនោះដោយសារថា :

ក./ ឃើញមានទំនោរថ្មីៗ លេចចេញមក

ខ./ ឃើញមានបរិមាណផ្សេងៗចូលរួម

គ./ ឃើញមានពន្លឺចេញពីប្រភពនៃការផ្គត់ផ្គង់សារធាតុទាំងនោះ រឺ

ឃ./ ឃើញមានវិធីផ្សេងៗ ដែលអ្នករត់ពន្ធខុសច្បាប់ប្រើប្រាស់ ។

របាយការណ៍ចតចំលងត្រូវជំរាបជូនស្របតាមវគ្គ ខនៃមាត្រា ២១ ។

៤. ភាគីត្រូវផ្តល់ជូនទៅក្រុមប្រឹក្សានូវរបាយការណ៍ស្ថិតិប្រចាំឆ្នាំ តាមសំណុំរូបមន្តដែលបានរៀបចំឡើងដោយក្រុមប្រឹក្សា :

ក./ ចំពោះសារធាតុនៃតារាងទី១ និងទី២នីមួយៗ ស្តីពីបរិមាណដែលត្រូវយកទៅផលិត នាំចេញ និងនាំចូលមកពីប្រទេសរឺ តំបន់នីមួយៗ ព្រមទាំងស្តុកដែលបានធ្វើឡើងដោយអ្នកផលិត

ខ./ ចំពោះសារធាតុនៃតារាងទី៣ និងទី៤នីមួយៗ ស្តីពីបរិមាណដែលយកទៅធ្វើ ព្រមទាំងពីបរិមាណសរុបដែលបាននាំចេញ និងនាំចូល

គ./ ចំពោះសារធាតុនៃតារាងទី២ និងទី៣នីមួយៗ ស្តីពីបរិមាណដែលប្រើប្រាស់សំរាប់ការធ្វើនៃការផ្សំ ដែលបានលើកលែង និង

ឃ./ ចំពោះសារធាតុដែលបានចុះក្នុងតារាងមួយផ្សេងពីតារាទី១នីមួយ១ ស្តីពីបរិមាណប្រើប្រាស់ក្នុងគោលដៅឧស្សាហកម្ម ស្របតាមបទបញ្ញត្តិនានានៃវគ្គ ខ របស់មាត្រា៤ ។

ចំពោះបរិមាណដែលបានធ្វើដូចមានចែងក្នុងវគ្គ ក និង ខ នៃកថាខ័ណ្ឌនេះ មិនរួមបញ្ចូលនូវបរិមាណនៃការផ្សំ ដែលបានធ្វើរួចហើយនោះទេ ។

៥. ភាគីត្រូវផ្តល់ជូនក្រុមប្រឹក្សា តាមការស្នើសុំរបស់ក្រុមប្រឹក្សា នូវពត៌មានស្ថិតិបន្ថែមដែលទាក់ទងទៅនឹងរយៈពេលដែលនឹងមាន ស្តីពីបរិមាណនៃសារធាតុផ្ទាល់ខ្លួន ក្នុងតារាងទី៣ និងទី៤ ដែលនាំចេញ និងនាំចូល ពីប្រទេស រឺ តំបន់នីមួយ១ ។ ភាគីនោះអាចស្នើសុំអោយក្រុមប្រឹក្សាលាក់ជាសំងាត់ ចំពោះការស្នើសុំពត៌មានរបស់ក្រុមប្រឹក្សា ទាំងចំពោះពត៌មានដែលផ្តល់ទៅអោយក្រុមប្រឹក្សា តាមកថាខ័ណ្ឌនេះ ។

៦. ភាគីត្រូវផ្តល់ពត៌មានដូចចែងក្នុងកថាខ័ណ្ឌទី១ និងទី៤ ទៅតាមរបៀប និងទៅតាមកាលបរិច្ឆេទដែលគណៈកម្មការ រឺក្រុមប្រឹក្សាអាចស្នើសុំ ។

មាត្រា១៧ : មុខងាររបស់គណៈកម្មការ

១. គណៈកម្មការអាចពិនិត្យរាល់បញ្ហាទាំងអស់ដែលទាក់ទងនឹងគោលបំណងនៃអនុសញ្ញានេះ ហើយដែលទាក់ទងនឹងការអនុវត្តបទបញ្ញត្តិនៃអនុសញ្ញានេះ និងធ្វើអនុសាសន៍ពាក់ព័ន្ធនឹងរឿងទាំងនោះ ។

២. ការសំរេចរបស់គណៈកម្មការ ដូចបានគ្រោងទុកក្នុងមាត្រា២ និងមាត្រា ៣ ត្រូវយកជាបានការដោយភាគច្រើន ពីរភាគបី នៃចំនួនសមាជិករបស់គណៈកម្មការ ។

មាត្រា១៨ : របាយការណ៍របស់ក្រុមប្រឹក្សា

១. ក្រុមប្រឹក្សារៀបចំរបាយការណ៍ប្រចាំឆ្នាំ ស្តីពីការងាររបស់ខ្លួន ដោយមាននិយាយពីការវិភាគពត៌មានស្ថិតិដែលក្រុមប្រឹក្សាមាន ហើយក្នុងករណីសមស្របត្រូវមាននិយាយពីសេចក្តីរាយការណ៍ពន្យល់ដែលរដ្ឋាភិបាលទាំងឡាយបានប្រគល់អោយ រឺដែលរដ្ឋាភិបាលត្រូវបានគេស្នើសុំអោយប្រគល់អោយ ព្រមទាំងការសង្កេត និងអនុសាសន៍ដែលក្រុមប្រឹក្សាចង់ជំរាបបញ្ជាក់ប្រាប់ ។ ក្រុមប្រឹក្សាអាចធ្វើគ្រប់របាយការណ៍ទាំងអស់បន្ថែមបាន បើក្រុមប្រឹក្សាយល់ថាចាំបាច់ ។ របាយការណ៍ត្រូវបង្ហាញជូនក្រុមប្រឹក្សាតាមរយៈគណៈកម្មការ ហើយគណៈកម្មការអាចបញ្ជាក់ពីការសង្កេតដែលគណៈកម្មការអាចធ្វើចំណាប់អារម្មណ៍ដែលខ្លួនយល់ឃើញថាត្រឹមត្រូវ ។

២. របាយការណ៍របស់ក្រុមប្រឹក្សា ត្រូវជូនដំណឹងទៅភាគីទាំងឡាយហើយ ត្រូវយកទៅផ្សព្វផ្សាយនាពេលក្រោយដោយអគ្គលេខាធិការ ។ ភាគីត្រូវតែអនុញ្ញាតអោយមានការចែកចាយរបាយការណ៍នេះដោយសេរី ។

មាត្រា១៩ : និតិវិធីនានាដែលអនុញ្ញាតការត្រួតពិនិត្យមានដើម្បីធានាការអនុវត្តបទបញ្ញត្តិនៃអនុសញ្ញា

